# មហាសតិប្បដ្ឋានសូត្រ

## (សេចក្តីសង្ខេប)



ប្រែសម្រួល និងរៀបរៀង

ដោយលោក ព្រំ ស្វីណា

ព.ស ២៥៥៣ គ.ស ២០០៨

# មាតិកា


- ឧទ្ទេសវារកថា ........................................ ១
- សតិបដ្ឋានទាំង ៤ តើអ្វីខ្លះ ........................................ ៣
- នេះជាផ្លូវមូលតែមួយ ........................................ ៦
- ដើម្បីសេចក្តីបរិសុទ្ធនៃសត្វទាំងឡាយ ........................................ ១១
- ដើម្បីលះបង់នូវសេចក្តីសោកនិងសេចក្តីខ្សឹកខ្សួល ........................................ ១២
- ដើម្បីរំលត់បង់នូវទុក្ខនិងទោមនស្ស ........................................ ១២
- ដើម្បីបាននូវអរិយមគ្គប្រកបដោយអង្គ ៨ ប្រការ ........................................ ១៥
- ការត្រាស់ដឹង ........................................ ១៦
- ដើម្បីធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន ........................................ ១៨
- សតិ ........................................ ១៨
- បដ្ឋាន ........................................ ២០
- ការចម្រើនសតិ ........................................ ២០
- ពិចារណាឃើញនូវកាយក្នុងកាយជាប្រក្រតី ........................................ ២២
- អាតាបី ........................................ ២២
- ជាអ្នកដឹងខ្លួន ........................................ ២៥

- សមាធិ .......... ២៦
- ធាតុផ្សំនៃការប្រតិបត្តិ .......... ៣០
- ធាតុផ្សំដែលកំពុងធ្វើការយ៉ាងស្អិតរមួត .......... ៣១
- លទ្ធផលនៃសមាធិ .......... ៣៥
- ការកម្ចាត់បង់ .......... ៣៥
- នៅពេលយើងមានសតិជាគ្រឿងកំណត់ .......... ៣៧
- កម្ចាត់បង់កិលេសទាំងឡាយ .......... ៣៨
- ខណិកបហានៈ .......... ៤១
- វិក្ខម្ភនបហានៈ .......... ៤២
- សមុច្ឆេទបហានៈ .......... ៤២
- អភិជ្ឈានិងទោមនស្ស .......... ៤៥
- សតិប្បដ្ឋាន ៤ .......... ៤៦
- ពិចារណានូវធម៌ .......... ៥០
- នៅក្នុងការប្រតិបត្តិ .......... ៥១
- អានិសង្សនៃការចម្រើនសតិប្បដ្ឋាន .......... ៥៤
- ពីព្រោះហេតុនេះ ព្រះពុទ្ធទ្រង់សម្ដែងថា .......... ៥៦
- សតិប្បដ្ឋានទាំង ៤ តើអ្វីខ្លះ។ .......... ៥៧

## មហាសតិប្បដ្ឋានសុត្តំ

ឯកាយនោ អយំ ភិក្ខវេ មគ្គោ
សត្តានំ វិសុទ្ធិយា
សោកបរិទេវានំ សមតិក្កមាយ
ទុក្ខទោមនស្សានំ អត្ថង្គមាយ
ញាយស្ស អធិគមាយ
និព្វានស្ស សច្ឆិកិរិយាយ
យទិទំ ចត្តារោ សតិប្បដ្ឋានា ។
កតមេ ចត្តារោ ។
ឥធ ភិក្ខវេ ភិក្ខុ
កាយេ កាយានុបស្សី វិហរតិ អាតាបី
សម្បជានោ សតិមា វិនេយ្យ លោកេ
អភិជ្ឈាទោមនស្សំ
វេទនាសុ វេទនានុបស្សី វិហរតិ អាតាបី
សម្បជានោ សតិមា វិនេយ្យ លោកេ
អភិជ្ឈាទោមនស្សំ

ចិត្តេ ចិត្តានុបស្សី វិហរតិ អាតាបី
សម្បជានោ សតិមា វិនេយ្យ លោកេ
អភិជ្ឈាទោមនស្សំ
ធម្មេសុ ធម្មានុបស្សី វិហរតិ អាតាបី
សម្បជានោ សតិមា វិនេយ្យ លោកេ
អភិជ្ឈាទោមនស្សំ ។

ឧទ្ទេសវារកថា និដ្ឋិតា ។

# មហាសតិប្បដ្ឋានសូត្រ

ម្នាលភិក្ខុទាំងឡាយ ផ្លូវគឺសតិប្បដ្ឋានទាំង ៤ នេះ ជាផ្លូវមូលតែមួយ (ប្រព្រឹត្តទៅ)

ដើម្បីសេចក្តីបរិសុទ្ធនៃសត្វទាំងឡាយ

ដើម្បីលះបង់នូវសេចក្តីសោកនិងសេចក្តីខ្សឹកខ្សួល

ដើម្បីរំលត់បង់នូវសេចក្តីទុក្ខនិងទោមនស្ស

ដើម្បីបាននូវអរិយមគ្គប្រកបដោយអង្គ ៨ ប្រការ

ដើម្បីធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន ។

## សតិប្បដ្ឋានទាំង ៤ តើអ្វីខ្លះ ។

ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ពិចារណាឃើញនូវកាយក្នុងកាយជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ មានព្យាយាមជាគ្រឿងដុតកម្តៅកិលេស ជាអ្នកដឹងខ្លួន មានស្មារតី (ជាគ្រឿងកំណត់) កម្ចាត់បង់ នូវអភិជ្ឈានិងទោមនស្ស ក្នុងលោកចេញ ១

ពិចារណាឃើញនូវវេទនាក្នុងវេទនាទាំងឡាយ ជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ មានព្យាយាមជាគ្រឿងដុតកម្តៅកិលេស ជាអ្នកដឹងខ្លួន មានស្មារតី (ជាគ្រឿងកំណត់) កម្ចាត់បង់ នូវអភិជ្ឈានិងទោមនស្ស ក្នុងលោកចេញ ១

ពិចារណាឃើញនូវចិត្តក្នុងចិត្តជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ មានព្យាយាមជាគ្រឿងដុតកម្តៅកិលេស ជាអ្នក

ដឹងខ្លួន មានស្មារតី (ជាគ្រឿងកំណត់) កម្ចាត់បង់ នូវអភិជ្ឈា និងទោមនស្ស ក្នុងលោកចេញ ១

ពិចារណាឃើញនូវធម៌ក្នុងធម៌ទាំងឡាយ ជាប្រក្រតី គ្រប់ឥរិយាបទទាំង៤ មានព្យាយាមជាគ្រឿងដុតកម្តៅកិលេស ជាអ្នកដឹងខ្លួន មានស្មារតី (ជាគ្រឿងកំណត់) កម្ចាត់បង់ នូវអភិជ្ឈានិងទោមនស្ស ក្នុងលោកចេញ ១ ។

ចប់ ឧទ្ទេសវារកថា ។

## នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

សូមនមស្ការថ្វាយបង្គំ ចំពោះព្រះដ៏មានព្រះភាគ ជាអរហន្ត សម្មាសម្ពុទ្ធ ព្រះអង្គនោះ ។

*ថ្ងៃនេះ ខ្ញុំសូមពន្យល់នូវអត្ថបទដកស្រង់ខ្លីៗ ដែលយើងសូត្ររៀងរាល់ព្រឹក ។ អត្ថបទនេះដកស្រង់ចេញពីព្រះសូត្រមួយឈ្មោះថា "សតិប្បដ្ឋានសូត្រ" ។ អត្ថបទដកស្រង់នេះ គ្រាន់តែជាឧទ្ទេសវារកថានៃសតិប្បដ្ឋាន ប៉ុន្តែ វាមានសារៈសំខាន់ណាស់សម្រាប់អ្នកដែលចម្រើនសតិប្បដ្ឋាន ឬវិបស្សនា ដើម្បីយល់ដឹងអត្ថបទដកស្រង់នេះឲ្យបានត្រឹមត្រូវ និងច្បាស់លាស់ ។*

*ដូចខ្ញុំបាននិយាយ វិធីសាស្ត្រចម្រើនសតិ ឬសតិប្បដ្ឋានទាំង ៤ រកឃើញដោយព្រះសម្មាសម្ពុទ្ធ ។ ព្រះអង្គបានចម្រើនដោយព្រះអង្គផ្ទាល់ ព្រមទាំងទទួលបានលទ្ធផលប្រសើរបំផុតពីការចម្រើននេះ បន្ទាប់មកព្រះអង្គបានបង្រៀនសតិប្បដ្ឋានទាំង ៤ នេះជាច្រើនដង ក្នុងរយៈពេល ៤៥ ព្រះវស្សា ។ បន្ទាប់ពីព្រះអង្គបរិនិព្វាន វិធីសាស្ត្រទាំងនេះ បានត្រូវប្រមូលរៀបរៀង និងចារទុកនៅក្នុងព្រះត្រៃបិដក ។ ការបង្រៀនទាំងអស់នៅក្នុងមជ្ឈមណ្ឌលវិបស្សនានេះ សុទ្ធតែផ្អែកលើមហាសតិប្បដ្ឋានសូត្រដែលរួមមានអត្ថបទដកស្រង់នេះ ។*

## នេះជាផ្លូវមូលតែមួយ

ឃ្លាមួយដំបូង "ម្នាលភិក្ខុទាំងឡាយ ផ្លូវគឺសតិប្បដ្ឋានទាំង ៤ នេះ ជាផ្លូវមូលតែមួយ (ប្រព្រឹត្តទៅ ) ដើម្បីសេចក្តីបរិសុទ្ធនៃសត្វទាំងឡាយ ដើម្បីបានន្ទូវអរិយមគ្គប្រកបដោយអង្គ ៨ ប្រការ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន ។ " ដូច្នេះ ដំបូងព្រះពុទ្ធទ្រង់សម្តែងថា "នេះជាផ្លូវមូលតែមួយ "។ សតិប្បដ្ឋាន គឺជាផ្លូវមូលតែមួយ ប្រព្រឹត្តទៅ ដើម្បីសេចក្តីបរិសុទ្ធនៃសត្វទាំងឡាយ ។ ត្រង់ នេះ ព្រះពុទ្ធទ្រង់សម្តែងថា "នេះជាផ្លូវមូលតែមួយ "។

នេះជាផ្លូវមូលតែមួយ ពាក្យជាភាសាបាលីថា **ឯកាយ នោ ។ ឯកាយនោ** ផ្សំមកពីពាក្យ **ឯក** និង **អយន។ អយន** មានន័យថា ផ្លូវ មគ្គ ឬមាគ៌ា រីឯ **ឯក** មានន័យថា មួយ។ ដូច្នេះ **ឯកាយនោ** មានន័យថា ផ្លូវមូលតែមួយ ។ ផ្លូវមូលតែ មួយ គឺផ្លូវមួយមិនមានបែកទៅជាផ្លូវ ២ ឬជាផ្លូវ ៣ **ឯកមគ្គោ ន ទ្វិធាបថភូតោ** ។ មានតែផ្លូវមួយ ហើយប្រសិនបើធ្វើដំណើរតាមផ្លូវនេះ នោះពិតជា នឹងបានទៅដល់គោលដៅយ៉ាងពិតប្រាកដ ។ មិនមានផ្លូវបែកនាំទៅខុសគោលដៅនោះទេ ។ ន័យមួយទៀត លោកថា ជាផ្លូវដែលត្រូវដើរបានតែមនុស្សម្នាក់ **ឯកេនេវ អយិតព្វោ** ព្រោះសតិប្បដ្ឋានទាំង ៤ នេះ បានតែ

ព្រះយោគីដែលលះបង់ពួកចេញហើយទៅសម្ងំ នៅក្នុងទីស្ងាត់ម្នាក់ឯង ទើបប្រតិបត្តិកើត **គណសង្គណិកំ បហាយ វូបកាដ្ឋេន បវិវិត្តចិត្តេន** ។

មួយទៀត លោកថា ជាផ្លូវរបស់មនុស្សប្រសើរ **ឯកាស្ស អយនោ** គឺថា ជាផ្លូវរបស់ព្រះសម្មាសម្ពុទ្ធ ព្រោះព្រះអង្គប្រសើរជាងសត្វទាំងពួងផង ហើយទ្រង់បានបង្កើតផ្លូវ គឺសតិប្បដ្ឋានឲ្យកើតមានឡើងផង ។ ន័យមួយទៀត ជាផ្លូវមាននៅក្នុងធម្មវិន័យនេះតែមួយ មិនមាននៅក្នុងសាសនាដទៃ **ឯកាស្មឹ អយនោ** ជាផ្លូវមូលតែមួយ ព្រោះជាផ្លូវប្រតិបត្តិ មិនមានផ្លូវដទៃផ្សេងទៀតប្រព្រឹត្តទៅ ដើម្បីសេចក្ដីបរិសុទ្ធនៃសត្វទាំងឡាយ ជាដើម ។ មានសំនួរពីរទាក់ទងនឹងពាក្យថា "ផ្លូវមូលតែមួយ "។ ទីមួយ សួរថា "តើសតិប្បដ្ឋានទាំង ៤ សំដៅត្រឹម **សតិ** តែមួយឬ "។ ឆ្លើយថា មានអង្គផ្សេងៗទៀតនៃអរិយមគ្គ ។ សួរថា "អង្គផ្សេងទៀតនៃអរិយមគ្គ ជាផ្លូវប្រតិបត្តិ ប្រព្រឹត្តទៅ ដើម្បីសេចក្ដីបរិសុទ្ធនៃសត្វទាំងឡាយមែន ឬមិនមែន "។ ឆ្លើយថា អង្គនៃអរិយមគ្គ ក៏ជាផ្លូវប្រតិបត្តិ ប្រព្រឹត្តទៅ ដើម្បីសេចក្ដីបរិសុទ្ធនៃសត្វទាំងឡាយ...” ប៉ុន្តែអង្គនៃអរិយមគ្គ មិនអាចកើតមាន ដោយគ្មានសតិបាននោះទេ ។ ហេតុដូច្នេះ នៅពេលនិយាយពីសតិ ក៏ប្រៀបដូចជានិយាយ

ពីអង្គដទៃទៀតនៃអរិយមគ្គដែរ ។ ទោះបីទីនេះពោលតែពីសតិ គប្បីយល់ថា អង្គទាំងអស់ទាំង ៧ ផ្សេងទៀត ដែលនៅរួមជាមួយ អរិយមគ្គក៏ត្រូវបានពោលផងដែរ ។

សំនួរមួយផ្សេងទៀតដែលគេសួរ ពិសេសនៅបច្ចឹម ប្រទេសគឺ "ហេតុអ្វីបានជាព្រះសម្មាសម្ពុទ្ធសម្តែងថា "នេះជាផ្លូវ មូលតែមួយ?" មិនមានផ្លូវដទៃទៀត ប្រព្រឹត្តទៅ ដើម្បីសេចក្តី បរិសុទ្ធនៃសត្វទាំងឡាយទេឬ?" ពួកគេឲ្យហេតុផលថា មានផ្លូវ ផ្សេងៗចូលទៅទីក្រុង ដូច្នេះមានផ្លូវផ្សេងៗទៅកាន់ទីក្រុង ត្រូវតែ មានផ្លូវផ្សេងទៀត ប្រព្រឹត្តទៅដើម្បីសេចក្តីបរិសុទ្ធនៃសត្វទាំង ឡាយ ឬផ្លូវប្រតិបត្តិ ដើម្បីចេញចាកសង្សារទៅកាន់ព្រះនិព្វាន ។ មនុស្សមួយចំនួនមិនចូលចិត្តដូច្នេះទេ ពួកគេគិតថា ព្រះពុទ្ធទ្រង់ មិនគួរសម្តែងថា "នេះជាផ្លូវមូលតែមួយ" ទេ ។ យ៉ាងណាក៏ដោយ ពេលខ្លះពាក្យប្រៀបធៀបសុទ្ធតែត្រូវទាំងអស់នោះទេ ។ ជាការ ពិត មានផ្លូវខុសគ្នាទៅកាន់ទីក្រុង (ខ្ញុំស្គាល់ប្រទេសនេះមិនទាន់ ច្បាស់ ដូច្នេះខ្ញុំមិនដឹងផ្លូវណាខ្លះទៅកាន់ទីក្រុងនោះទេ )។ ទាំង នេះសុទ្ធតែផ្លូវ មិនមែនវាលភក់ ឬទីព្រៃនោះទេ ។ ដូច្នេះ ផ្លូវគឺ គ្រាន់តែជាផ្លូវដើម្បីធ្វើដំណើរទៅកាន់ទីក្រុង ។ អាចមានផ្លូវខុសៗ គ្នា ប៉ុន្តែសុទ្ធតែជាផ្លូវទាំងអស់ ។ ដូចគ្នានេះដែរ អាចមានផ្លូវ ផ្សេងៗដើម្បីចម្រើនសតិ ប៉ុន្តែផ្លូវប្រតិបត្តិទាំងនោះត្រូវតែជាសតិ។

មានតែសតិមួយទេ ដែលអាចនាំយើងចេញចាកសង្សារទៅកាន់ព្រះនិព្វាន **ឯកំ អយតីតិ** ។ ពាក្យប្រៀបធៀបមួយទៀត ប្រសិនបើយើងនិយាយថា ការហាត់ប្រាណ ជាវិធីតែមួយគត់ ដើម្បីឲ្យមានសាច់ដុំ ខ្ញុំគិតថាគ្មាននរណាម្នាក់ជំទាស់នឹងបញ្ហានេះទេ ។ ប្រសិនបើលោកអ្នកចង់បានសាច់ដុំធំ លោកអ្នកត្រូវតែហាត់ប្រាណ ។ បើគ្មានការហាត់ប្រាណទេ លោកអ្នកមិនអាចសង្ឃឹមថាមានសាច់ដុំធំនោះទេ ។ ការហាត់ប្រាណអាចមានទម្រង់ខុសៗគ្នា ដូចជាការលើកអាល់តែរ ឬការប្រើម៉ាស៊ីន ជាដើម ។ ដូចគ្នានេះដែរ សតិគឺជាផ្លូវតែមួយគត់ ដើម្បីចេញចាកសង្សារទៅកាន់ព្រះនិព្វាន ប៉ុន្តែសតិអាចមានទម្រង់ខុសៗគ្នា ។ សូម្បីនៅក្នុងមហាសតិប្បដ្ឋានសូត្រនេះ ការចម្រើនសតិត្រូវបានបង្រៀនម្តែមួយវិធីសាស្រ្ត ។ មានការចម្រើនសតិ ២១ បែបខុសៗគ្នា ដើម្បីជ្រើសរើស ។ ដូច្នេះ ខ្ញុំគិតថា ជាការត្រឹមត្រូវក្នុងការនិយាយថានេះជាផ្លូវមូលតែមួយ ។ សតិប្បដ្ឋានជាផ្លូវមូលតែមួយ ។

គេអាចជជែកពិភាក្សានៅត្រង់ចំនុចនេះ ពីព្រោះពាក្យដែលប្រើទីនេះគឺ "**ឯកាយន**" ផ្លូវមូលតែមួយ ។ មួយវិញទៀតនៅក្នុងធម្មបទ ព្រះពុទ្ធទ្រង់បានសម្តែងយ៉ាងច្បាស់ថា "ផ្លូវនេះ ឯងប្រព្រឹត្តទៅដើម្បីសេចក្តីបរិសុទ្ធនៃទស្សនៈ ផ្លូវដទៃមិនមាន ទេ" "**ឯសេវ មគ្គោ នត្ថញ្ញោ**" (បិដកលេខ ៥២ ធម្មបទ មគ្គវគ្គទី ២០

ទំព័រ ៧៨ )។ ដូច្នេះយើងមិនអាចឲ្យហេតុផលថា ព្រះពុទ្ធទ្រង់បានសម្តែងថា ផ្លូវដទៃមាននោះទេ ។ ព្រះអង្គបានសម្តែងយ៉ាងច្បាស់ថា ផ្លូវនេះឯង ជាផ្លូវមូលតែមួយ ហើយផ្លូវដទៃមិនមានឡើយ ។ ដូច្នេះខ្ញុំគិតថា យើងគប្បីទទួលយកថា នេះជាផ្លូវមូលតែមួយ ប្រព្រឹត្តទៅ ដើម្បីសេចក្តីបរិសុទ្ធនៃសត្វទាំងឡាយ ។ បើយើងពិចារណាបញ្ហានេះ ដោយយោងទៅតាមការប្រតិបត្តិ វារឹតតែច្បាស់ថែមទៀត ។

ខ្ញុំបាននិយាយថា សតិប្រៀបដូចជា អ្នកយាមទ្វារ ហើយនៅពេលអ្នកយាមទ្វារត្រូវបានដកចេញ អ្វីមួយអាចចូលទៅខាងក្នុងបាន ។ ដូច្នេះ គ្រប់ពេលដែលសតិស្ថិតនៅក្នុងទ្វារវិញ្ញាណ ចិត្តរបស់យើងបរិសុទ្ធ ។ គ្មានអកុសលអាចកើតមាននៅក្នុងចិត្តរបស់យើង ពីព្រោះសតិស្ថិតនៅទីនោះដើម្បីការពារទ្វារវិញ្ញាណ។ យ៉ាងណាក៏ដោយ នៅពេលសតិត្រូវបានដកចេញ ឬនៅពេលយើងបាត់សតិ កិលេសទាំងអស់នឹងចូលទៅខាងក្នុង ។ ដូច្នេះសតិគឺជាផ្លូវតែមួយ ដើម្បីការពាររក្សាចិត្តឲ្យបរិសុទ្ធ ។ ចូរកត់សម្គាល់ត្រង់នេះដែរថា សតិគឺជាអង្គមួយក្នុងចំណោមអង្គទាំង ៨ ប្រការនៃអរិយមគ្គនៅក្នុងធម្មបទ ហើយប្រសិនបើអរិយមគ្គមានអង្គ ៨ ជាផ្លូវមូលតែមួយ ដូច្នេះសតិពិតជាផ្លូវមូលតែមួយផងដែរ ។

មួយវិញទៀត សតិអាចមានទម្រង់ខុសៗគ្នា ដូចជា **កាយានុសតិ** ការរលឹកនូវកាយ **វេទនានុសតិ** ការរលឹកនូវវេទនា **ចិត្តានុសតិ** ការរលឹកនូវចិត្ត **ធម្មានុសតិ** ការរលឹកនូវធម៌ ឬ **សីវថិកានុសតិ** ការរលឹកនូវអាការៈ ៣២ ប្រការ ជាដើម ។ ប្រសិនបើ ជាសតិ ដូច្នេះសតិជាផ្លូវមូលតែមួយ ប្រព្រឹត្តទៅ ដើម្បីសេចក្តីបរិសុទ្ធនៃសត្វទាំងឡាយ ។

## ដើម្បីសេចក្តីបរិសុទ្ធនៃសត្វទាំងឡាយ

"ដើម្បីសេចក្តីបរិសុទ្ធនៃសត្វទាំងឡាយ" មានន័យថា ដើម្បីសេចក្តីបរិសុទ្ធនៃចិត្តរបស់សត្វទាំងឡាយ ។ ពីព្រោះព្រះពុទ្ធទ្រង់សម្តែងទាក់ទងនឹងសេចក្តីបរិសុទ្ធផ្លូវចិត្ត ជាងសេចក្តីបរិសុទ្ធផ្លូវកាយ ទោះបីមិនមានន័យថា យើងមិនត្រូវយកចិត្តទុកដាក់នឹងភាពស្អាតបរិសុទ្ធនៃរាងកាយក៏ដោយ អ្វីដែលសំខាន់ជាងសម្រាប់យើង គឺសេចក្តីបរិសុទ្ធនៃចិត្តរបស់យើង ។ ហេតុដូច្នេះ សេចក្តីបរិសុទ្ធនៃសត្វទាំងឡាយ មានន័យថាសេចក្តីបរិសុទ្ធនៃចិត្តរបស់សត្វទាំងឡាយ ។

អដ្ឋកថាសម្តែងថា ទាំងសេចក្តីបរិសុទ្ធផ្ទាល់ខ្លួន ឬសេចក្តីបរិសុទ្ធនៃរាងកាយទាំងសេចក្តីបរិសុទ្ធនៃទីកន្លែង ជួយឲ្យសម្រេចបានសមាធិ និងបញ្ញា ។ ដូច្នេះ យើងក៏ត្រូវការរក្សាកាយរបស់

យើងឲ្យបានស្អាត ព្រមទាំងរក្សាទឹកនៃ្ទងដែលយើងចម្រើនសមាធិឲ្យបានស្អាតផងដែរ ។ យ៉ាងណាក៏ដោយ ទោះបីយើងមិនយកចិត្តទុកដាក់នឹងភាពស្អាតបរិសុទ្ធនៃរាងកាយ យើងគប្បីខ្វល់ខ្វាយនឹងសេចក្ដីបរិសុទ្ធនៃចិត្តជាង ។ នេះព្រះពុទ្ធទ្រង់សម្ដែងថា សតិគឺជាផ្លូវមួលតែមួយ ប្រព្រឹត្តទៅ ដើម្បីសេចក្ដីបរិសុទ្ធនៃសត្វទាំងឡាយ ។

## ដើម្បីលះបង់នូវសេចក្ដីសោកនិងសេចក្ដីខ្សឹកខ្សួល

បន្ទាប់មក ព្រះពុទ្ធទ្រង់សម្ដែងថា "ដើម្បីលះបង់នូវសេចក្ដីសោកនិងសេចក្ដីខ្សឹកខ្សួល"។ ប្រសិនបើយើងចង់លះបង់សេចក្ដីសោកនិងសេចក្ដីខ្សឹកខ្សួល ឬការទួញសោក យើងគប្បីចម្រើនសតិ ។ សតិជាផ្លូវមូលតែមួយ ដើម្បីលះបង់នូវសេចក្ដីសោកនិងសេចក្ដីខ្សឹកខ្សួល ។ សេចក្ដីសោកជាចេតសិក ឯសេចក្ដីខ្សឹកខ្សួលគឺជាការទួញសោកតាមរយៈសេចក្ដីសោក ហើយនិយាយពីនេះពីនោះ ។ បើតាមអត្ថបទដកស្រង់នេះ ដើម្បីលះបង់នូវសេចក្ដីសោកនិងសេចក្ដីខ្សឹកខ្សួល យើងគប្បីចម្រើនសតិ ។

## ដើម្បីរំលត់បង់នូវទុក្ខនិងទោមនស្ស

"ដើម្បីរំលត់បង់នូវទុក្ខនិងទោមនស្ស", "ទុក្ខ" មានន័យថាសេចក្ដីទុក្ខផ្លូវកាយ សេចក្ដីទុក្ខនៅក្នុងរាងកាយ ហើយ

"**ទោមនស្ស**" មានន័យថា សេចក្តីទុក្ខផ្លូវចិត្ត សេចក្តីសៅហ្មងចិត្ត ព្យាបាទៈ ទោសៈ ទាំងអស់រួមបញ្ចូលក្នុងពាក្យ "**ទោមនស្ស**"។ ដើម្បីរំលត់បង់ និងដើម្បីឲ្យអស់ទៅនូវទុក្ខនិងទោមនស្ស យើងគប្បីចម្រើនសតិ ។ ដូចដែលខ្ញុំបាននិយាយ អ្នកមិនអាចយកឈ្នះលើសេចក្តីទុក្ខ អ្នកមិនអាចរំលត់បង់នូវទុក្ខទាំងស្រុងបានទេ សេចក្តីទុក្ខមិនអាចបាត់ទៅទាំងស្រុងឡើយ ប៉ុន្តែ ប្រសិនបើអ្នកចម្រើនសតិ អ្នកអាចរស់នៅជាមួយសេចក្តីទុក្ខ ព្រមទាំងទទួលយកសេចក្តីទុក្ខ ។ ដូចចិត្តរបស់ព្រះអនុរុទ្ធ ចិត្តរបស់អ្នកនឹងមិនបានធាតៅ ឬរំខានដោយសេចក្តីទុក្ខផ្លូវកាយ ។ ប្រសិនបើចិត្តមិនបានរំខាន ដោយសេចក្តីទុក្ខផ្លូវកាយ សេចក្តីទុក្ខមិនកើតឡើងដោយជាក់ស្តែង ។ ដូច្នេះ ដើម្បីឲ្យអស់ទៅនូវទុក្ខ និងដើម្បីរំលត់បង់នូវទុក្ខ យើងគប្បីចម្រើនសតិ ។ ដើម្បីរំលត់បង់នូវទោមនស្ស ព្យាបាទៈ សេចក្តីសៅហ្មងចិត្ត ជាដើម យើងគប្បីចម្រើនសតិ ។ ទោមនស្សគឺ ជាចេតសិក ហើយសេចក្តីសោកសៅក៏ជាចេតសិកផងដែរ ។ ទោមនស្សនិងសេចក្តីសោកសៅទាក់ទងគ្នាដោយពិត។ ទោមនស្ស និងសេចក្តីសោកសៅអាចរំលត់បង់ ឬធ្វើឲ្យបាត់ទៅ ឬអាចចៀស ផុតបានដោយការចម្រើនសតិ ។

ចិត្តមិនអាចទទួលយកអារម្មណ៍ពីរ ឬច្រើនជាងមួយ នៅពេលតែមួយបានទេ ។ ចិត្តអាចទទួលយកអារម្មណ៍តែមួយគត់

ក្នុងពេលតែមួយ ។ ខ្ញុំគិតថា យើងទាំងអស់គ្នាមានសំណាង ។ ប្រសិនបើចិត្តអាចទទួលយកអារម្មណ៍ពីរ ឬច្រើនជាងពីរ ក្នុងពេលតែមួយ សេចក្ដីទុក្ខរបស់យើងកាន់តែធំទ្វេរឡើងថែមទៀត។ ដោយសារតែចិត្តអាចទទួលយកអារម្មណ៍តែមួយ ក្នុងពេលតែមួយ យើងអាចរំលត់បង់នូវសេចក្ដីសោក សេចក្ដីទោមនស្ស ដោយការចម្រើនសតិ ។ ជាតួយ៉ាង សូមលើកយកសេចក្ដីក្រោធមកជាឧទាហរណ៍ ។ ឧបមាថា ខ្ញុំខឹងនឹងលោកក ពេលណាចិត្តរបស់ខ្ញុំស្ថិតនៅលើលោកក សេចក្ដីក្រោធខឹងនឹងកើនឡើង ហើយខ្ញុំកាន់តែខឹងនឹងលោកក ពីព្រោះខ្ញុំកំពុងយកលោកកជាអារម្មណ៍នៃចិត្តរបស់ខ្ញុំ ។ ប៉ុន្ដែនៅពេលខ្ញុំត្រឡប់ចិត្តរបស់ខ្ញុំពីលោកកដែលជាប្រភពនៃសេចក្ដីក្រោធ ទៅលើសេចក្ដីក្រោធ ហើយខណៈពេលខ្ញុំត្រឡប់ចិត្តរបស់ខ្ញុំ ទៅដាក់លើសេចក្ដីក្រោធ លោកកមិនកើតមាន សម្រាប់ខ្ញុំនៅខណៈពេលនោះ ។ លោកកបានបាត់ពីចិត្តរបស់ខ្ញុំ ។ នៅពេលចិត្តរបស់ខ្ញុំស្ថិតនៅលើសេចក្ដីក្រោធព្រមទាំង នៅពេលដែលប្រភពនៃសេចក្ដីក្រោធបានបាត់ទៅ សេចក្ដីក្រោធក៏ត្រូវតែបាត់ទៅផងដែរ ។

តាមវិធីនេះ យើងចម្រើនចេតសិកបែបនេះ ជាមួយសតិជាមួយសតិសាមញ្ញ ប៉ុន្ដែខ្លាំង ឬមានថាមពល ។ នេះជារបៀបដែលយើងដោះស្រាយជាមួយអ្វីដែលយើងហៅថា អារម្មណ៍ផ្លូវ

ចិត្ត ដូចជា ឧបាទាន សេចក្តីក្រោធ ទោសៈ សេចក្តីសៅហ្មង សេចក្តីសោកសៅ ។ ចេតសិកអ្វីក៏ដោយ យើងគ្រាន់តែចម្រើនវាជាមួយសតិ ព្រមទាំងព្យាយាមមានសតិពិនិត្យមើលវា។ នៅពេលដែលសតិរបស់យើងកាន់តែមាំ ចេតសិកទាំងនេះនឹងរលត់បាត់ទៅជាប្រាកដ ។ ព្រះពុទ្ធសម្តែងថា "សតិប្បដ្ឋានទាំង ៤ នេះ ជាផ្លូវមូលតែមួយ ប្រព្រឹត្តទៅ ដើម្បីលះបង់នូវសេចក្តីសោកនិងសេចក្តីខ្សឹកខ្សួល ដើម្បីរំលត់បង់នូវទុក្ខនិងទោមនស្ស"។

## ដើម្បីបាននូវអរិយមគ្គប្រកបដោយអង្គ ៨ ប្រការ

"សតិប្បដ្ឋានទាំង ៤ នេះ ជាផ្លូវមូលតែមួយ ប្រព្រឹត្តទៅ ដើម្បីបាននូវអរិយមគ្គប្រកបដោយអង្គ ៨ ប្រការ"។ នៅពេលដែលលោកអ្នកអានសៀវភៅស្តីពីព្រះពុទ្ធសាសនា លោកអ្នកឃើញពាក្យ "មគ្គ", "ផ្លូវ" ជាច្រើនដង ។ "មគ្គ" ជាពាក្យបាលី ជាឈ្មោះសម្រាប់រួមបញ្ចូល ឬក្រុមនៃមគ្គប្រកបដោយអង្គ ៨ ប្រការ គឺ **សម្មាទិដ្ឋិ** សេចក្តីយល់ឃើញត្រូវ១ **សម្មាសង្កប្ប** សេចក្តីត្រិះរិះត្រូវ ១ **សម្មាវាចា** ការនិយាយពាក្យត្រូវ ១ **សម្មាកម្មន្តៈ** ការងារត្រូវ១ **សម្មាអាជីវៈ** ការចិញ្ចឹមជីវិតត្រូវ ១ **សម្មាវាយាមៈ** សេចក្តីព្យាយាមត្រូវ ១ **សម្មាសតិ** សេចក្តីនឹករលឹកត្រូវ ១ **សម្មាសមាធិ** ការតម្កល់ចិត្តឲ្យនឹងត្រូវ ១ ដែលកើតឡើងនៅខណៈ

ដែលត្រាស់ដឹង។ ប្រភេទនៃចិត្ត ដែលប្រកបដោយអង្គទាំងនេះ ហៅថា "**មគ្គចិត្ត**"។

## ការត្រាស់ដឹង

ពាក្យថា "ការត្រាស់ដឹង" ជាពាក្យមួយទៀត ដែលអត្ថន័យរបស់វា មិនងាយស្រួលដល់ការយល់ ។ នៅពេលដែលគេប្រើពាក្យនេះឲ្យកាន់តែទូលំទូលាយបន្តិច មានតិចនាក់ណាស់ដែលអាចយល់អត្ថន័យរបស់វាដោយត្រឹមត្រូវ ។ បើគ្មានការពន្យល់ទេ អត្ថន័យរបស់វាស្រពិចស្រពិល ។ វាអាចមានអត្ថន័យខុសៗគ្នា ចំពោះបុគ្គលផ្សេងៗគ្នា ឬសាសនាផ្សេងៗគ្នា ពោលគឺ ការត្រាស់ដឹង សម្រាប់ពុទ្ធសាសនិកជន ពិតជាខុសគ្នាពីការត្រាស់ដឹងរបស់គ្រឹស្តសាសនិក ។

អាស្រ័យហេតុនេះ មុននឹងយើងពិភាក្សាពីការត្រាស់ដឹង យើងគប្បីឲ្យនិយមន័យវាជាមុន ។ បើតាមព្រះពុទ្ធសាសនា ការត្រាស់ដឹងមានន័យថា ការរំលត់បង់ទាំងស្រុងនូវកិលេស ហើយមើលឃើញព្រះនិព្វានដោយផ្ទាល់ មើលឃើញព្រះនិព្វានដោយចំពីមុខ ក្នុងពេលតែមួយ ។ ដូចយោគីចម្រើនវិបស្សនា និងចម្រើនឡើងពីដំណាក់មួយទៅដំណាក់មួយទៀត ឈានដល់ដំណាក់ខ្ពស់មួយហើយមួយទៀត ជាលទ្ធផលនៃការចម្រើនវិបស្សនានេះ

ពេលវេលាក៏ចូលមកដល់ នៅក្នុងចិត្តរបស់យោគី ប្រភេទនៃចិត្តមួយកើតឡើង នោះហើយដែលយោគីនោះមិនធ្លាប់បានឃើញពីមុន ។ ប្រភេទនៃចិត្តនោះរួមជាមួយចេតសិករបស់វា មានកម្លាំងយ៉ាង ខ្លាំងក្លា អាចរំលត់បង់នូវកិលេសទាំងស្រុងបាន ដោយមិនត្រឡប់មកវិញ ។ ក្នុងពេលដំណាលគ្នានេះ ចិត្តរបស់យោគីក៏ចាប់យកព្រះនិព្វានមកជាអារម្មណ៍ ។ ដូច្នេះ អ្វីដែលយើងចង់មាន ន័យដោយការត្រាស់ដឹងគឺជាអ្វីដែលកើតនៅខណៈនោះ ពេលគឺខណៈពេលដែលចិត្តនោះកើតឡើង និងរំលត់បង់នូវកិលេសទាំងស្រុង ព្រមទាំងចាប់យកព្រះនិព្វានមកជាអារម្មណ៍ ។

ចិត្តដែលកើតឡើងនោះ ឈ្មោះថា "**មគ្គចិត្ត**"។ ផលចិត្តកើតពីរឬបីខណៈ ភ្លាមៗបន្ទាប់ពីមគ្គចិត្ត ។ អ្នកគប្បីយល់ធម៌អភិធម្ម ដើម្បីយល់ដឹងការណ៍នេះឲ្យបានពេញលេញ ។ ដូច្នេះ ដើម្បីបាន នូវអរិយមគ្គប្រកបដោយអង្គ ៨ ប្រការ មានន័យជាសាមញ្ញថា ដើម្បីទទួលបាននូវការត្រាស់ដឹង ។ នៅពេលលោកអ្នកឈានដល់អរិយមគ្គយ៉ាងពិតប្រាកដ លោកអ្នកនឹងបានត្រាស់ដឹង ហើយលោកអ្នកអាចបន្សាត់បង់នូវកិលេស ព្រមទាំងចាប់យកព្រះនិព្វាន មកជាអារម្មណ៍ ។

## ដើម្បីធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន

"សតិប្បដ្ឋានទាំង ៤ នេះ ជាផ្លូវមួលតែមួយ ប្រព្រឹត្តទៅដើម្បីធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន"។ នេះក៏ដូចគ្នានឹងការបាននូវអរិយមគ្គប្រកបដោយអង្គ ៨ ប្រការដែរ ។ ដូច្នេះ នៅពេលដែលយោគីបាននូវអរិយមគ្គ នៅពេលដែលមគ្គចិត្តកើតឡើង ហើយមគ្គចិត្តនោះចាប់យកព្រះនិព្វានមកជាអារម្មណ៍ នោះហើយគឺជាពេលដែលគេនិយាយថា យោគីបានធ្វើឲ្យជាក់ច្បាស់នូវព្រះ និព្វាន ។ ព្រោះហេតុនេះ ការបាននូវអរិយមគ្គ និងការធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វានមានន័យតែមួយ ។ ព្រះពុទ្ធទ្រង់សម្តែងថា "ការចម្រើនសតិជាផ្លូវមូលតែមួយ ប្រព្រឹត្តទៅ ដើម្បីសេចក្តីបរិសុទ្ធនៃចិត្តរបស់យើង ផ្លូវមូលតែមួយ ដើម្បីលះបង់នូវសេចក្តីសោកនិងសេចក្តីខ្សឹកខ្សួល ដើម្បីរំលត់បង់នូវទុក្ខនិងទោមនស្សដើម្បីបាននូវអរិយមគ្គប្រកបដោយអង្គ ៨ ប្រការ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន ។

## សតិ

ទីនេះយើងក៏មានពាក្យ "**បដ្ឋាន**"និងពាក្យ "**សតិ**"។ ដំបូងគប្បីយល់អ្វីទៅជាសតិ ។ យើងទាំងអស់គ្នាបានចម្រើនសតិប្រហែលអស់រយៈពេលជាច្រើនឆ្នាំ ប៉ុន្តែពេលខ្លះ គេសួរយើងថា

"អ្វីទៅជាសតិ"។ យើងប្រហែលជាមិនអាចផ្តល់ចម្លើយជាទីគាប់ចិត្តបានទេ ។ **សតិ** ជាពាក្យបាលី ។ សូត្រនេះឈ្មោះថា **សតិប្បដ្ឋាន** ដូច្នេះអ្នកមានពាក្យសតិនៅទីនេះ ។ ប្រហែលជាគ្មានពាក្យណាមួយប្រសើរជាងនេះទេ ។ **សតិ** មានន័យថា ការចងចាំ ប៉ុន្តែវាគ្របដណ្តប់លើការចងចាំ បើតាមពិតទៅ ។ តាមនិរុត្តិសាស្ត្រ សតិមានន័យថាជ្រៅជាងនេះ ។ នៅក្នុងអដ្ឋកថា **សតិ** មានន័យ ថា ការរឭកបាន ហើយលក្ខណៈរបស់សតិគឺ "មិនរង្គើ" មានន័យ ថា "មិនអណ្តែតនៅលើផ្ទៃ (នៃអារម្មណ៍)"។ ប្រសិនបើវាជាសតិ វាមិនត្រូវនៅ សើៗទេ វាត្រូវចូលទៅជ្រៅនៅក្នុងអារម្មណ៍ ។ ហេតុនេះហើយ ខ្ញុំតែងតែនិយាយថា "ការរឭកពេញលេញនូវអារម្មណ៍"។ លោកថា សតិមានការមិនបាត់អារម្មណ៍ជាកិច្ច ។ ពេលណាមានសតិ យើង មិនបាត់អារម្មណ៍នោះទេ យើងមិនភ្លេចអារម្មណ៍នោះទេ ។ សតិមានការមិនបាត់អារម្មណ៍ ឬការភ្លេចអារម្មណ៍ជាកិច្ច ។ វាដូចជា ឆ្មាំយាមទ្វារនៅឯទ្វារ ។ នោះគឺអ្វីដែលយើងហៅសតិ ។ សតិគឺមិនមែនការរឭកសើៗទេ គឺការរឭកពេញលេញ ឬជ្រៅទៅក្នុងអារម្មណ៍ ។ សតិក្នុងទីនេះ សំដៅយក **សម្មាសតិ** គឺការរលឹកឃើញដោយប្រពៃ ក្នុងការចម្រើនវិបស្សនា ពុំមែនសំដៅយកសតិធម្មតានោះទេ ។ សតិធម្មតា គឺសំដៅយកការរលឹកដឹងដោយប្រុងប្រយ័ត្ន ដូចនៅពេលយើងចាប់កាន់កែវ ឬ

ចានជាដើម ត្រូវដឹងថា យើងកំពុងចាប់កាន់អ្វី ហើយត្រូវប្រុងប្រយ័ត្នកុំឲ្យវាធ្លាក់បែក ។ សតិប្រភេទនេះជាទូទៅគឺត្រូវបានប្រើនៅក្នុងជីវិតប្រចាំថ្ងៃរបស់យើង ។

## **បដ្ឋាន**

**បដ្ឋាន** មានន័យថា ការតម្កល់ ឬការទ្រ ឬជើងទ្រ ដូច្នេះ "**សតិប្បដ្ឋាន**" មានន័យថា "ការតម្កល់សតិ" ឬ "សតិដែលមានគ្រឿងតម្កល់មាំ"។ ពាក្យបាលី "**សតិប្បដ្ឋាន**" ប្រែថា "ការតម្កល់មាំនៃសតិ" ប៉ុន្តែយើងគប្បីយល់ដោយន័យថាការតម្កល់សតិដ៏មាំ ឬការបង្កើតសតិដ៏មាំ ។ ដូច្នេះ ការចម្រើន ឬការតម្កល់នៃសតិដ៏ មាំ ហៅថា សតិប្បដ្ឋាន ។

## **ការចម្រើនសតិ**

នៅក្នុងព្រះសូត្រនេះ ព្រះពុទ្ធទ្រង់សម្តែងថា មានសតិប្បដ្ឋាន ៤ ។ នៅពេលដែលអ្នកចម្រើនវិបស្សនានៅក្នុងទីស្ងាត់បែបនេះ អ្នកចម្រើនសតិប្បដ្ឋានទាំងអស់៤នេះ ប៉ុន្តែ អ្នកចម្រើនព្រាវៗមិនមែនម្តងមួយៗតាមលំដាប់នៅក្នុងព្រះសូត្រនោះទេ ។ នេះពីព្រោះ នៅពេលដែលលោកអ្នកចម្រើនវិបស្សនា លោកអ្នកត្រូវនឹករលឹកដល់អារម្មណ៍ នៅខណៈពេលបច្ចុប្បន្ន ។ អ្នកមិនអាច

មានលទ្ធភាពមិនរឰកដល់អារម្មណ៍ ក្នុងខណៈពេលបច្ចុប្បន្ន ។ អារម្មណ៍ខណៈពេលបច្ចុប្បន្នអាចជាអារម្មណ៍មួយក្នុងចំណោម អារម្មណ៍ទាំង ៤ ពេលខ្វះកាយ ពេលខ្វះវេទនា ពេលខ្វះចិត្ត ពេលខ្វះធម៌ ។ អ្នកត្រូវតែទទួលយកអារម្មណ៍ទាំងនេះ នៅពេល ដែលវាកើតឡើង លោកអ្នកគ្មានជម្រើសទេ ។ ហេតុដូច្នេះហើយ ពេលខ្វះវិបស្សនាឈ្មោះថា "ការដឹងច្បាស់គ្មានជម្រើស"។ នេះ មានន័យថា លោកអ្នកគ្មានជម្រើសទេ ពោលគឺ លោកអ្នកគ្រាន់ តែត្រូវទទួលយកអ្វីដែលកើតឡើងដល់លោកអ្នក ។ ហេតុដូច្នេះ លោកអ្នកចម្រើនសតិប្បដ្ឋានទាំង ៤ នេះ មិនតម្រូវឲ្យជាក់លាក់ ចំពោះអារម្មណ៍តែមួយទេ ក្នុងពេលលោកអ្នកចម្រើនវិបស្សនា ។

ត្រង់នេះហើយ ព្រះពុទ្ធទ្រង់បង្រៀនយើងពីរបៀបចម្រើន សតិប្បដ្ឋានទាំង ៤ ។ សតិប្បដ្ឋានទាំង ៤ តើអ្វីខ្វះ ។ "ម្នាលភិក្ខុ ទាំងឡាយ ភិក្ខុក្នុងសាសនានេះ ពិចារណាឃើញនូវកាយក្នុង កាយជាប្រក្រតី គ្រប់ឥរិយាបទទាំង ៤ មានព្យាយាមជាគ្រឿងដុត កម្តៅកិលេស ជាអ្នកដឹងខ្លួន មានស្មារតី (ជាគ្រឿងកំណត់) កម្ចាត់បង់នូវអភិជ្ឈានិងទោមនស្ស ក្នុងលោកចេញ"។ នេះជា ប្រយោគខ្លីមួយ ប៉ុន្តែវាមានអត្ថន័យច្រើន ។

## ពិចារណាឃើញនូវកាយក្នុងកាយជាប្រក្រតី

"ពិចារណាឃើញនូវកាយក្នុងកាយជាប្រក្រតី" មានន័យ ថា នៅពេលភិក្ខុចម្រើនកាយានុសតិ ភិក្ខុនោះជាក់ច្បាស់ ។ ភិក្ខុ ពិចារណាឃើញកាយក្នុងកាយ និងមិនពិចារណាឃើញវេទនា នៅក្នុងកាយ ឬមិនពិចារណាឃើញបុគ្គលនៅក្នុងកាយ ជាដើម ។ ភិក្ខុពិចារណាឃើញកាយនៅក្នុងកាយ ។ ដើម្បីឲ្យមានអារម្មណ៍ ជាក់ច្បាស់ ព្រះពុទ្ធទ្រង់សម្តែងឡើងវិញពាក្យ "**កាយ**" "**វេទនា**" "**ចិត្ត**" និង "**ធម៌**" នេះមានន័យថា ភិក្ខុជាក់ច្បាស់នៅក្នុងសតិរបស់ ខ្លួនផ្នែកកាយ វេទនា ចិត្ត និងធម៌ ។ នៅពេលភិក្ខុចម្រើន **កាយានុបស្សនា** ភិក្ខុមានព្យាយាមជាគ្រឿងដុតកម្តៅកិលេស ជាអ្នកដឹងខ្លួន មានស្មារតីជាគ្រឿងកំណត់ ។

## អាតាបី

ពាក្យថា "**អាតាបី**" ជាពាក្យបាលី មានន័យថា គ្រឿងដុត កម្តៅ ។ ជួនកាល នាំឲ្យបាត់អត្ថន័យ ពេលដែលយើងបកប្រែពី ភាសាមួយទៅភាសាមួយទៀត ។ ពាក្យ **អាតាបី** មកពីពាក្យ **អាតាបៈ** ។ **អាតាបៈ** មានន័យថា "កម្តៅព្រះអាទិត្យ"។ កម្តៅព្រះ អាទិត្យអាចដុតវត្ថុផ្សេងៗ ដូច្នេះ វត្ថុនោះក្លាយទៅជាស្វិត ហើយ អាចទៅជាខ្មោច ។ ដូចគ្នានេះដែរ សេចក្តីព្យាយាមដុតកម្តៅ

កិលេស ដូច្នេះ ហៅថា **អាតាបៈ** ជាភាសាបាលី ហើយយោគីអ្នកមានអាតាបៈ ឈ្មោះថា **អាតាបី** ។ បច្ច័យ "ឦ" សម្គាល់កម្មសិទ្ធិ ហេតុដូច្នេះ អ្នកមានអាតាបៈ ឈ្មោះថា អាតាបី ។ នៅពេលយើងអានព្រះសូត្រជាភាសាបាលី ហើយអានពាក្យអាតាបី នោះគឺអ្វីដែលយើងមាននៅក្នុងចិត្តរបស់យើង គឺយើងឃើញ សេចក្តីព្យាយាមដុតកម្តៅកិលេស។ អាតាបី មានន័យថា យោគីមានសេចក្តីព្យាយាមពិតប្រាកដ មិនមែនសេចក្តីព្យាយាមធូររលុងពោលគឺ សេចក្តីព្យាយាមពិតប្រាកដ ដើម្បីតម្កល់សតិ និងដើម្បីរឭកបានយ៉ាងច្បាស់ ។

នៅពេលព្រះសម្មាសម្ពុទ្ធនៅជាពោធិសត្វ ទ្រង់បានអង្គុយនៅក្រោមដើមពោធិ ដើម្បីប្រតិបត្តិក្លាយជាព្រះពុទ្ធ ព្រះអង្គបានអធិដ្ឋានយ៉ាងមាំនៅក្នុងចិត្តរបស់ព្រះអង្គថា"សូមឲ្យស្បែក សរសៃនិងឆ្អឹងរបស់អាត្មាអញនៅ សូមឲ្យសាច់និងឈាមរបស់អាត្មាអញរីងស្ងួតទៅ ប៉ុន្តែអាត្មាអញនឹងមិនឈប់ ឬលះបង់ចោលសេចក្តីព្យាយាមផុតវិស័យមនុស្ស រហូតបានត្រាស់ដឹង ។ អាត្មាអញនឹងមិនក្រោកចាកអាសនៈ រហូតដល់បានត្រាស់ដឹង ។ អាត្មាអញនឹងព្យាយាមរហូតដល់បានសម្រេចគោលបំណង ។ សេចក្តីព្យាយាមបែបនេះ ឈ្មោះថា "សេចក្តីព្យាយាមត្រូវ"។ ដើម្បីធ្វើឲ្យមានសេចក្តីព្យាយាមត្រូវ មានន័យថា យោគីគប្បីប្រារព្ធសេចក្តី

ព្យាយាមល្អ មិនមែនសេចក្ដីព្យាយាមធូររលុងទេ ។ ពាក្យថា អាតាបី បញ្ជាក់នូវអត្ថន័យទាំងអស់នេះ ។ សេចក្ដីព្យាយាមត្រូវ ដែលគប្បីយល់នៅទីនេះគឺ សេចក្ដីព្យាយាមត្រូវដែលជាអង្គមួយ ក្នុងចំណោមអង្គទាំង ៨ ប្រការនៃអដ្ឋង្គិកមគ្គ (អរិយមគ្គប្រកប ដោយអង្គ ៨ ប្រការ)។ (លោកអ្នកប្រហែលជាបានអាន អំពី សេចក្ដីព្យាយាមត្រូវ នៅក្នុងសៀវភៅដទៃទៀត)។ សេចក្ដី ព្យាយាមត្រូវ មានន័យថា ការផុសខាត់ ឬការចៀសវាងនូវ អកុសលចេតសិកទាំងឡាយ (អំពើជាអកុសល) និងការធ្វើឲ្យ មានឡើង ឬការធ្វើឲ្យច្រើនឡើងនូវកុសលចេតសិក (អំពើជា កុសល)។ ដើម្បីទប់កុំឲ្យមានអកុសលចេតសិក ដើម្បីទប់កុំឲ្យមាន អំពើអកុសល លោកអ្នកត្រូវការសេចក្ដីព្យាយាមផ្លូវចិត្ត ។ ប្រសិន បើលោកអ្នកមិនប្រារព្ធសេចក្ដីព្យាយាមផ្លូវចិត្តនេះទេ លោកអ្នក មិនអាចទប់កុំឲ្យមានអំពើអកុសលបានទេ ។ ហេតុដូច្នេះ សេចក្ដី ព្យាយាមសំខាន់ណាស់សម្រាប់ការទប់កុំឲ្យមាន ឬការផុសខាត់ នូវអកុសលចេតសិក និងសម្រាប់ការធ្វើឲ្យមានឡើង ឬការធ្វើឲ្យ ចម្រើនឡើងនូវកុសលចេតសិក លោកអ្នកត្រូវការសេចក្ដី ព្យាយាម។ ប្រសិនបើលោកអ្នកមិនប្រារព្ធសេចក្ដីព្យាយាម លោក អ្នកមិនមកកន្លែងស្ងាត់ដូចនេះឡើយ ។ លោកអ្នកត្រូវការសេចក្ដី ព្យាយាមពិតប្រាកដ សេចក្ដីព្យាយាមដ៏ខ្លាំងក្លា ដើម្បីចម្រើន

សតិប្បដ្ឋាន ។ សរុបសេចក្ដីមក ព្រះពុទ្ធទ្រង់ពណ៌នាភិក្ខុទីនេះថា ជាអ្នកមានសេចក្ដីព្យាយាម ដែលមានន័យថា អ្នកមានប្រភេទនៃសេចក្ដីព្យាយាមដែលដុតកម្ដៅកិលេស ហើយនេះត្រូវបានបង្ហាញដោយពាក្យ អាតាបី នៅក្នុងគម្ពីរជាភាសាបាលី ។

## ជាអ្នកដឹងខ្លួន

ឃ្លាបន្ទាប់គឺ "ជាអ្នកដឹងខ្លួន"។ ជាអ្នកដឹងខ្លួន ឬមានសម្បជញ្ញៈ មានន័យថា ការឃើញយ៉ាងច្បាស់ ។ អារម្មណ៍អ្វីក៏ដោយដែលភិក្ខុផ្ដង់ចិត្តលើ ភិក្ខុឃើញអារម្មណ៍នេះយ៉ាងច្បាស់ ។ តើ "យ៉ាងច្បាស់" មានន័យដូចម្ដេច ។ ភិក្ខុឃើញអារម្មណ៍គ្រប់ពេលវេលា ឃើញដោយបញ្ញា ។ ជាតួយ៉ាង នៅពេលដែលយោគីតាំងសតិឲ្យមានមុខឆ្ពោះទៅរកខ្យល់ដង្ហើម យោគីឃើញនូវខ្យល់ដង្ហើមយ៉ាងច្បាស់ ។ យោគីឃើញខ្យល់ដង្ហើមចូលដោយឡែកពីខ្យល់ដង្ហើមចេញ និងខ្យល់ដង្ហើមចេញដោយឡែកពី ខ្យល់ដង្ហើមចូល យោគីឃើញផងដែរថា ខ្យល់ដង្ហើម (អស្សាសបស្សាសៈ) កើតឡើងហើយរលត់ទៅវិញ ហើយនៅខណៈនោះ មានតែខ្យល់ដង្ហើម និងការដឹងខ្យល់ដង្ហើមយ៉ាងច្បាស់ និងគ្មានអ្វីដទៃទៀតដែលហៅថា សត្វ ឬបុគ្គលនោះទេ ។ សេចក្ដីយល់ឃើញបែបនេះឈ្មោះថា "ជាអ្នកដឹងខ្លួន"។ នៅពេលអ្នកមានសម្បជញ្ញៈអំពីអ្វី

មួយ អ្នកដឹងនូវវត្ថុនោះ និងលក្ខណៈទាំងអស់របស់វា ។ យោង តាមពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ អ្នកក៏ដឹងផងដែរថា មានតែ វត្ថុដែលគេពិនិត្យមើល និងចិត្តដែលពិនិត្យមើល ហើយគ្មានអ្វី ដទៃដែលអ្នកអាចហៅថា សត្វ បុគ្គល មនុស្សប្រុស ឬមនុស្សស្រី ទេ។ ការឃើញតាមរបៀបនេះហៅថាជាអ្នកដឹងខ្លួន ។ សម្បជញ្ញៈ នឹង កើតឡើងតែបន្ទាប់ពីពេលខ្លះ មិនកើតឡើងនៅពេលដំបូង នោះទេ ។ លោកអ្នកចម្រើនសតិ ប៉ុន្តែនៅពេលចាប់ផ្តើមដំបូង លោក អ្នកប្រហែលមិនអាចសូម្បីឃើញនូវខ្យល់ដង្ហើមយ៉ាង ច្បាស់ផង ។ ជួនកាល ខ្យល់ដង្ហើមទាំងនោះរួមបញ្ចូលគ្នា ហើយ ស្រពិច ស្រពិល ។ បន្តិចម្តងៗ ជាមួយការចម្រើនឡើងនូវសមាធិ របស់អ្នក និងការបដិបត្តិ អ្នកនឹងឃើញអារម្មណ៍ កាន់តែច្បាស់ ឡើងៗ បន្ទាប់មកការកើតឡើងនិងការរលត់ទៅវិញនៃអារម្មណ៍ នោះផងដែរ ។ ដូច្នេះ សម្បជញ្ញៈនេះកើតឡើងមិនមែននៅពេល ដំបូងទេ ប៉ុន្តែបន្ទាប់ពីយោគីទទួលបាននូវបទពិសោធន៍ ។

## សមាធិ

ដើម្បីឲ្យសម្បជញ្ញៈកើតមានឡើង យើងត្រូវការរបស់មួយ ទៀត ។ ទោះបីជាមិនមានសម្តែងនៅក្នុងព្រះសូត្រនេះក្តី យើង ត្រូវការរបស់មួយទៀត ពោលគឺ សមាធិ ។ បើគ្មានសមាធិទេ សម្ប

ជញ្ញា:មិនអាចកើតឡើងបានឡើយ ។ អ្វីទៅជាសមាធិ ។ សមាធិគឺជាសភាពនៃចិត្ត ដែលរក្សាធាតុផ្សំនៃចិត្តឲ្យមានមុខឆ្ពោះទៅរកអារម្មណ៍តែមួយ និងទប់ធាតុផ្សំនៃចិត្តមិនឲ្យទៅរកអារម្មណ៍ផ្សេងទៀត។ នោះគឺអ្វីដែលយើងហៅថាសមាធិ។ ជាធម្មតា លោកពណ៌នា សមាធិថាជាចិត្តដែលអាចផ្តងលើអារម្មណ៍បានយ៉ាង យូរ ។ ជាតួយ៉ាង បើអ្នកយកខ្យល់ដង្ហើមមកជាអារម្មណ៍ ចិត្តរបស់អ្នកតែងតែ ស្ថិតនៅលើខ្យល់ដង្ហើមហើយចិត្តនោះមិនទៅទីណាផ្សេងឡើយ ។ តាមពិត គ្រប់ខណៈទាំងអស់ សភាពចិត្តដែលហៅថាសមាធិក៏រក្សាចិត្ត និងធាតុផ្សំរបស់វា (ចេតសិក) ឲ្យនៅរួមជាមួយអារម្មណ៍ផងដែរ វារក្សាចិត្តនិងចេតសិកនៅជាមួយគ្នាព្រមទាំងគៀកមិនឲ្យចិត្ត និងចេតសិកឃ្លាតទៅរក អារម្មណ៍មួយផ្សេងទៀត។ សមាធិនេះសំខាន់សម្រាប់ឲ្យសម្បជញ្ញ:កើតឡើង។ បើគ្មានភាវនានេះទេ យើងមិនអាចសង្ឃឹមថា មើលឃើញធម្មជាតិបានច្បាស់ទេ ។ យើងមិនអាចសង្ឃឹមថា ទទួលបានសម្បជញ្ញ:ភាពជាអ្នកដឹងខ្លួននោះក៏ទេដែរ ។

នៅពេលដែលយើងមានសមាធិ ចិត្តរបស់យើងស្ងប់ ស្ងាត់ (ចាកភាគ:) និងជាពេលដែលយើងចាប់ផ្តើមមើលឃើញធម្មជាតិតាមសភាវ:ពិត ។ ចិត្តប្រៀបដូចទឹក ។ ដំបូងមានធូលី ឬភក់នៅក្នុងទឹក ដូច្នេះយើងមិនអាចមើលអ្វីឃើញធ្លុងកាត់ទឹកនោះបាន ទេ

។ ប៉ុន្តែនៅពេលធូលី ឬភក់រងចុះ ទឹកឡើងថ្លា យើងអាចមើលឃើញអ្វីៗចុងកាត់ទឹកបាន ។ ដូច្នេះ ចិត្តរបស់យើងត្រូវការឲ្យដូចទឹក គឺថា ពីព្រោះមានធូលី ឬកិលេសជាច្រើននៅក្នុងចិត្តរបស់យើង ។ ពេលណាដែលចិត្តរបស់យើងធ្វើឲ្យមិនស្អាត ដោយកិលេស យើងមិនអាចមើលឃើញអ្វីៗបានច្បាស់លាស់តាមសភាវៈពិតរបស់វា ។ យើងត្រូវ ការសង្កត់សង្កិនកិលេសទាំងនេះដែលយើងហៅថា **នីវរណធម៌** ដូច្នេះយើងអាចមើលឃើញបានច្បាស់ ។ នៅពេលយើងមានសមាធិ យើងអាចសង្កត់សង្កិននីវរណធម៌បាន ។ នៅពេលដែល នីវរណធម៌ត្រូវបានសង្កត់សង្កិនឬធ្វើឲ្យស្ងាត់ ចិត្តទៅជាថ្លា ហើយ នេះជាពេលដែលសម្បជញ្ញៈ ឬ **យថាភូតញាណទស្សនៈ** (ការឃើញអ្វីៗតាមសភាវៈពិត) កើតមានឡើង ។

ដើម្បីឲ្យមានសម្បជញ្ញៈ យើងត្រូវការសមាធិដូចដែលខ្ញុំបានសម្តែង មិនមាននៅក្នុងព្រះសូត្រនេះទេ ។ ប៉ុន្តែយើងគប្បីទទួលយកថា សមាធិក៏រួមបញ្ចូលផងដែរនៅក្នុងអត្ថបទដកស្រង់នេះ ពីព្រោះបើគ្មានសមាធិទេ យើងមិនអាចទទួលបានសម្បជញ្ញៈបានទេ ។ ជួនកាលពាក្យខ្លះអាចមិនដាក់បញ្ចូល ប៉ុន្តែយើងគប្បីយល់ពាក្យទាំងនោះដូចដែលបានពោលមក តាមរយៈការសន្និដ្ឋាន ។ ឧបមា មានផ្ទាំងថ្មរាបស្មើមួយ ហើយព្រានកំពុងដេញ

តាមក្ដាន់មួយ ហើយព្រានបានឃើញស្នាមជើងនៅលើជ្រុងមួយ ប៉ុន្តែនៅលើផ្ទាំងថ្មព្រានមិនបានឃើញស្នាមជើងទេ ហើយម្ដង ទៀតព្រានបានឃើញស្នាមជើងនៅលើជ្រុងម្ខាងទៀត ។ គាត់បាន សន្និដ្ឋានថា ក្ដាន់ត្រូវតែរត់កាត់ផ្ទាំងថ្ម ។ ព្រានបានឃើញពីខាង ដើម និងខាងចុង ដូច្នេះព្រានសន្និដ្ឋានទីកណ្ដាលថា ក្ដាន់ត្រូវតែ រត់ឆ្លងកាត់ផ្ទាំងថ្ម ។ ដូចគ្នានេះដែរ មានស្មារតីគឺខាងដើម ហើយ ជាអ្នកដឹងខ្លួនគឺដូចខាងចុង ។ ដូច្នេះ នៅពេលទាំងពីរនេះត្រូវ បានពោល កណ្ដាលក៏ត្រូវបានពោលដោយជាក់ស្ដែង ពីព្រោះបើ គ្មានកណ្ដាល ពោលគឺសមាធិទេ ក៏គ្មានសម្បជញ្ញៈ (ខាងចុង) ផងដែរ ។ ពាក្យចុងក្រោយគឺមានសតិ ។ សតិទីនេះត្រូវបានដាក់ ខាងចុង ប៉ុន្តែតាមពិត នៅក្នុងការបដិបត្តិគេគួរដាក់បន្ទាប់ពី "មាន ព្យាយាមជាគ្រឿងដុតកម្ដៅកិលេស"។ យើងព្យាយាម ដូច្នេះយើង មានសតិ ។ យើងមានសតិ ដូច្នេះយើងមានសមាធិ ហើយសមាធិ នាំឲ្យមានសម្បជញ្ញៈ ។ យើងមាន "សតិ" នៅទីនេះ ប៉ុន្តែខ្ញុំបាន ពន្យល់ន័យសតិរួចហើយ ដូច្នេះខ្ញុំមិនចាំបាច់ពន្យល់ម្ដងទៀតទេ។

ភិក្ខុក្នុងសាសនានេះ ពិចារណាឃើញនូវកាយក្នុងកាយ ជាប្រក្រតី ។ ភិក្ខុក្នុងសាសនានេះចម្រើនកាយានុសតិ មាន ព្យាយាមជាគ្រឿងដុតកម្ដៅកិលេស ជាអ្នកដឹងខ្លួន មានសតិពេញ លេញផ្ដោះទៅរកអារម្មណ៍ មានសមាធិចិត្ត និងជាអ្នកដឹងខ្លួន ។

## ធាតុផ្សំនៃការប្រតិបត្តិ

ឥឡូវនេះ តើយើងមានធាតុផ្សំប៉ុន្មានហើយ ។ "មានព្យាយាមជាគ្រឿងដុតកម្ដៅកិលេស" ជាធាតុផ្សំមួយ "ជាអ្នកដឹងខ្លួន" ជាធាតុផ្សំមួយទៀត "សមាធិ" ក៏ជាធាតុផ្សំមួយទៀត "មានសតិ" ជាធាតុផ្សំមួយផ្សេងទៀត ។ ដូច្នេះ យើងមានចេតសិកបួននៅទីនេះ ។ ចេតសិកទាំងបួននេះ ជាធាតុផ្សំនៃការប្រតិបត្តិ ។ នៅពេលដែលយើងប្រតិបត្តិ គប្បីមានចេតសិកទាំងបួននេះធ្វើការរួមគ្នាដោយស្អិតរមួត ។ ប៉ុន្តែមានចេតសិកមួយថែមទៀត ដែលមិនបានសម្ដែងនៅទីនេះ នោះគឺ **សទ្ធា** ឬការជឿ ។ សទ្ធា ឬការជឿក៏ជាអង្គសំខាន់មួយផងដែរ ពីព្រោះប្រសិនបើយើងមិនមានសទ្ធានៅក្នុងការប្រតិបត្តិនេះទេ យើងក៏មិនប្រតិបត្តិដែរ ។ យើងពិតជាមិនមានសទ្ធាងងឹតងងល់ ប៉ុន្តែយើងមានសទ្ធា ឬការជឿនៅក្នុងព្រះពុទ្ធ និងព្រះធម៌ ។ យើងមានជំនឿថា គ្រាន់តែផ្ដោតការយកចិត្តទុកដាក់នឹងអារម្មណ៍ទាំងនេះ យើងនឹងអាចឃើញធម្មជាតិពិតនៃធម៌ទាំងឡាយនេះ ពោលគឺ **អនិច្ចំ** មិនទៀង **ទុក្ខំ** ជាទុក្ខ និង **អនត្តា** មិនមែនជារបស់ខ្លួន ។ ដូច្នេះ យើងគប្បីមានសទ្ធានោះឲ្យបានច្រើន ពីព្រោះបើគ្មានសទ្ធាទេ គ្មានការងារណាមួយអាចសម្រេចជោគជ័យបានទេ ។ អាស្រ័យហេតុនេះ សទ្ធាក៏ជាផ្នែកមួយនៃការចម្រើនសមាធិ ទោះបីជាវាមិនធ្វើការសកម្ម នៅ

ខណៈពេលកំពុងសមាធិ ឬចម្រើនសតិក៏ដោយ វានៅតែធ្វើការនៅទីនោះយ៉ាងស្អិតរមួតជាមួយអង្គដទៃទៀត ។ ដូច្នេះ យើងមានអង្គប្រាំរួមគ្នា ហើយអង្គទាំងប្រាំនេះ គេហៅថា **ឥន្ទ្រិយ៍ប្រាំ** ។ អាចារ្យបង្រៀនសមាធិ ចូលចិត្តនិយាយអំពីអង្គទាំងនេះណាស់។ អង្គទាំងប្រាំនេះត្រូវធ្វើការដំណាលគ្នា និងស្អិតរមួតជាមួយគ្នា ប្រសិនបើយើងមានការចម្រើនសមាធិល្អ ។

## ធាតុផ្សំដែលកំពុងធ្វើការយ៉ាងស្អិតរមួត

ដូចខ្ញុំបានសម្ដែង ដំបូងយើងអាចខ្វះសម្បជញ្ញៈ ប៉ុន្តែក្រោយមក នៅពេលដែលសមាធិរបស់យើងចម្រើនឡើង យើងនឹងអាចមើលឃើញអ្វីៗបានច្បាស់ ជាដើម ហើយអង្គទាំងប្រាំនេះនឹងធ្វើការយ៉ាងស្អិតរមួត ។ ចុះប្រសិនបើអង្គទាំងប្រាំមិនធ្វើការស្អិតរមួត យើងចាញ់ ។ នៅពេលដែលយើងកំពុងប្រតិបត្តិ ពិសេសសំខាន់គឺតុល្យភាពនៃវិរិយៈ សេចក្ដីព្យាយាមនិងសមាធិ។ ប្រសិនបើវិរិយៈនិងសមាធិមិនស្មើគ្នា ប្រសិនបើមានម្ខាងច្រើនហួស ឬម្ខាងទៀតច្រើនហួស យើងចាញ់ សមាធិរបស់យើងគ្មានអ្វីសោះ ។ វិរិយៈដែលយើងព្យាយាមត្រូវតែគ្រាន់តែគ្រប់គ្រាន់ មិនច្រើនពេក មិនតិចពេក ។ ជួនកាលយើងមានទំនោរព្យាយាមច្រើនពេក ពីព្រោះយើងចង់សម្រេចអ្វីមួយ យើងក្លាយទៅជាមាន

សេចក្តីលោភលន់តិចទៅវិញ ដូច្នេះយើងព្យាយាមបន្ថែមទៀត ។ នៅពេលយើងព្យាយាមថែមទៀត យើងអន្ទះអន្ទែងក្នុងខ្លួន រំជួលក្នុងចិត្ត បន្ទាប់មកយើងបាត់សមាធិ ។ ដូច្នេះ សេចក្តីព្យាយាមច្រើនពេកមិនធ្វើការនោះទេ ។ ចុះចំណែកសេចក្តីព្យាយាមតិចពេក ។ យើងទៅជាងងុយដេក ខ្ជិល ហើយយើងមិនអាចផ្តងស្មារតី និងមិនអាចប្រតិបត្តិផងដែរ ។ ដូច្នេះ សេចក្តីព្យាយាមគប្បីកុំច្រើនពេក ឬតិចពេក ។ នៅពេលមានសេចក្តីព្យាយាមច្រើនហួស មានសមាធិមិនគ្រប់គ្រាន់ ។ ចំពោះវិរិយៈនិងសមាធិ នៅពេលមួយឡើងខ្ពស់ មួយទៀតចុះទាប ។ វិរិយៈច្រើនពេក សមាធិធ្លាក់ចុះ ។ នៅពេលមានវិរិយៈតិចពេក ក៏សមាធិធ្លាក់ចុះដែរ ។ ទោះបីយ៉ាងណាក៏ដោយ សមាធិក៏មិនត្រូវច្រើនពេកដែរ ។ នៅពេលយើងមានសមាធិច្រើនពេក យើងមានទំនោរទៅជាខ្ជិល ។ យើងមានទំនោរចង់ធ្វើឲ្យវាងាយស្រួល ឬចង់ធ្វើឲ្យវិរិយៈរបស់យើងតិចចុះ ។

ឧបមាថា យើងកំពុងប្រតិបត្តិ ហើយយើងមានសមាធិល្អ។ នៅពេលយើងមានសមាធិល្អ យើងមិនចង់ព្យាយាមច្រើន ដូច្នេះយើងមានទំនោរចង់ធ្វើឲ្យវិរិយៈតិចចុះ ។ នៅពេលយើងធ្វើឲ្យវិរិយៈរបស់យើងតិចចុះ កម្រិតនៃវិរិយៈធ្លាក់ចុះ ហើយយើងទៅជាខ្ជិល ទៅជាងោកងុយ ។ នៅក្នុងករណីនេះ យើងត្រូវបង្កើនវិរិយៈ

របស់យើង ដោយព្យាយាមបន្ថែមទៀត និងយកចិត្តទុកដាក់យ៉ាង ស្និទ្ធ ឬពេលខ្វះ ដោយបន្ថែមអារម្មណ៍ខ្វះទៀត ដើម្បីពិចារណា ដូចជា អារម្មណ៍បីបន្តបន្ទាប់គ្នាជាលំដាប់ ។

ជួនកាលយើងកំពុងប្រតិបត្តិជាមួយសមាធិល្អ ភ្លាមៗមួយរំពេច យើងបាត់អស់សមាធិ ។ ប្រហែលមកពីយើងប្រឹងព្យាយាមច្រើនជាងដែលត្រូវការ ។ យើងចង់ធ្វើវាឲ្យប្រសើរ ដូច្នេះយើងព្យាយាមច្រើន ហើយលទ្ធផលគឺផ្ទុយពីអ្វីដែលយើងចង់បាន ។ ជួនកាល នៅពេលដែលអ្នកចម្រើនសមាធិ សមាធិរបស់អ្នកល្អ ប៉ុន្តែ ទោះបីសមាធិរបស់អ្នកល្អ អ្នកមានទំនោរទៅជាងងុយដេក ឬចាប់ផ្តើមងោកក្បាល ។ នោះមានន័យថា អ្នកមានសមាធិច្រើនពេក ។ ប្រសិនបើអ្នកមានសមាធិច្រើនពេក អ្នកគប្បីធ្វើឲ្យកម្រិតនៃសមាធិថយចុះដោយបន្ថែមសេចក្តីព្យាយាម ដោយយកអារម្មណ៍បន្ថែមទៀតក្នុងពេលតែមួយ ជាដើម ។ រួមសេចក្តីមកវីរិយៈនិងសមាធិគប្បីត្រូវមានតុល្យភាព ដូច្នេះយើងមានសមាធិ ល្អ និងសម្បជញ្ញៈ ។

ដូច្នេះ យើងអាចឃើញថា សមាធិមិនងាយស្រួលទេ ។ ខ្ញុំមិនចង់បំបាក់ទឹកចិត្តលោកអ្នកទេ ប៉ុន្តែសមាធិគឺមិនងាយស្រួល ទេ ។ វាងាយខូចណាស់ ។ គ្រាន់តែចេតសិកមិនស្មើគ្នាតូចមួយ អាចធ្វើឲ្យខូចសមាធិដែលអ្នកបានខិតខំព្យាយាមយ៉ាងសម្បើម ។

ដូច្នេះ ចេតសិកទាំងប្រាំនេះគប្បីធ្វើការដំណាលគ្នា និងគប្បីជាមួយគ្នាយ៉ាងស្អិតរមួត ។ សមាធិគឺដូចជាម៉ាស៊ីនអឺចឹង ។ មានផ្នែកជាច្រើននៅក្នុងម៉ាស៊ីន ហើយផ្នែកនីមួយៗត្រូវធ្វើការយ៉ាងត្រឹមត្រូវ ។ ប្រសិនបើផ្នែកមួយធ្វើការមិនត្រឹមត្រូវ ម៉ាស៊ីនទាំងមូលខូច (គ្រប់គ្រងមិនបាន)។ ដូចគ្នានេះដែរ ការងារទាំងមូលនៃសមាធិឃ្វាតចេញពីតុល្យភាព ។ ហេតុដូច្នេះ អង្គនីមួយៗនៃចេតសិកទាំងប្រាំនេះត្រូវធ្វើការយ៉ាងត្រឹមត្រូវ និងយ៉ាងស្អិតរមួតជាមួយអង្គដទៃទៀត ។

នេះគឺជាទីកន្លែងដែលតម្លៃនៃសតិកើតមានឡើង ពោលគឺសតិគឺជាចេតសិកធ្វើឲ្យនៅនឹង ដូច្នេះវាជួយរក្សាវីរិយៈកុំឲ្យច្រើនពេក វាជួយឲ្យសមាធិកុំឲ្យច្រើនពេក ជាដើម ។ សតិគឺជាអង្គធ្វើឲ្យនៅនឹង ក្នុងចំណោមធាតុផ្សំទាំងប្រាំនេះ នៅក្នុងការចម្រើនសមាធិ ។ ហេតុដូច្នេះហើយ គេនិយាយថា សតិតែងតែត្រូវការឲ្យមាន ដែលមិនអាចមានការច្រើនហួសកម្រិតនៃសតិ ។ សតិត្រូវការឲ្យមានគ្រប់ទីកន្លែង ប្រៀបដូចជាអំបិលបីចេងដែលតែងត្រូវការសម្រាប់គ្រប់មុខម្ហូប ឬប្រៀបដូចជា រាជអាមាត្រ ដែលធ្វើការទាំងអស់ជំនួសព្រះរាជា ។ ទោះបីយ៉ាងណាក៏ដោយ ខណៈពេលដែលសតិគឺជាអង្គសំខាន់មួយក្នុងចំណោមអង្គទាំងប្រាំ គ្រប់អង្គ

ទាំងអស់ក៏សំខាន់ដែរ ហើយអង្គនីមួយៗត្រូវធ្វើការយ៉ាងស្អិតរមួត និងមានតុល្យភាព (ស្មើគ្នា) នឹងអង្គដទៃទៀត ។

## លទ្ធផលនៃសមាធិ

នៅពេលដែលចេតសិកទាំងប្រាំធ្វើការស្មើគ្នា ហើយយោគីមានសម្បជញ្ញៈ តើលទ្ធផលដូចម្ដេច ។ លទ្ធផលគឺកម្ចាត់បង់នូវអភិជ្ឈានិងទោមនស្ស ក្នុងលោកចេញ ។ "**អភិជ្ឈា**" មានន័យថា ការប្រកាន់មាំ ហើយ "**ទោមនស្ស**" មានន័យថា ការព្យាបាទ ឬសេចក្ដីក្រោធ ។ នេះជាលទ្ធផលដែលយោគីទទួលបានពីសម្បជញ្ញៈ ក្នុងការចម្រើនសតិ ។

## ការកម្ចាត់បង់

ការបកប្រែជាច្រើន (ភាសាអង់គ្លេស) ខ្វះខាតចំណុច ។ គេបកប្រែថា "ការកម្ចាត់បង់" ឬ "បានបោះបង់" ឬ "បានបន្សាត់បង់" នូវអភិជ្ឈានិងទោមនស្ស ក្នុងលោកចេញ ។ តើការចម្រើនសតិនេះដើម្បីអ្វី ។ ឆ្លើយថាៈ ដើម្បីកម្ចាត់បង់នូវអភិជ្ឈា និងទោមនស្ស ។ វិបស្សនា ឬសតិប្បដ្ឋានភាវនាគឺដើម្បីកម្ចាត់បង់នូវអភិជ្ឈានិងទោមនស្ស ។ ប្រសិនបើបុគ្គលនោះបានកម្ចាត់បង់នូវអភិជ្ឈានិងទោមនស្សចេញរួចហើយ គេមិនចាំបាច់ត្រូវការការ

ប្រតិបត្តិទេ ។ វាសម្រាប់គោលបំណងនេះហើយ ដែលយើងកំពុងចម្រើនសតិ ប៉ុន្តែប្រសិនបើយើងបានសម្រេចនូវគោលបំណងនេះហើយ យើងមិនចាំបាច់ចម្រើនសតិនេះទេ ។ ដូច្នេះ ចំណុចនេះ យើងគប្បីបកប្រែថា "កម្ចាត់បង់ (ក្នុងពេលដំណាលគ្នា) នូវអភិជ្ឈានិងទោមនស្ស ក្នុងលោកចេញ" មិនមែន "បានកម្ចាត់បង់" ទេ ។ នេះមានន័យថា យោគីកម្ចាត់បង់អភិជ្ឈានិងទោមនស្ស ពេលចម្រើនសតិប្បដ្ឋាន ។ ខ្ញុំចង់ឲ្យលោកអ្នកដឹងច្បាស់អំពីចំណុចនេះ ។ ( ទីនេះសេចក្តីពន្យល់ យោងតាមវេយ្យាករណ៍ បាលីអាចមានប្រយោជន៍ ប៉ុន្តែដោយសារវាស្មុគស្មាញពេក ខ្ញុំគ្មានជម្រើស ប៉ុន្តែមិនអើពើដឹងមិនបាន )។

"កម្ចាត់បង់នូវអភិជ្ឈានិងទោមនស្ស ក្នុងលោកចេញ" មានន័យថា កម្ចាត់បង់នូវតណ្ហា ឬឧបាទាន ឬសេចក្តីក្រោធទាក់ទងទៅនឹងអារម្មណ៍ ដែលយោគីកំពុងកត់សម្គាល់ ។ លោកក្នុងទីនេះសំដៅយកកាយ ព្រោះកាយនេះ ជាសភាវៈតែងទ្រុឌទ្រោមវិនាសទៅជាធម្មតា មួយទៀត អភិជ្ឈានិងទោមនស្សដែលកិក្ខុលះបង់ក្នុងកាយនោះ មិនត្រឹមតែក្នុងកាយប៉ុណ្ណោះទេ សូម្បីតែអភិជ្ឈានិងទោមនស្សក្នុងពួកវេទនា សញ្ញា សង្ខារ វិញ្ញាណក៏ត្រូវលះបង់ដែរ ។ យើងឃើញអារម្មណ៍មួយ ហើយយើងអាចជាប់ជំពាក់ទៅនឹងអារម្មណ៍នោះ ។ ប្រសិនបើយើងឈានដល់សេចក្តីសន្និដ្ឋាន ថា

អារម្មណ៍នោះល្អ ឬស្រស់ស្អាត យើងជាប់ជំពាក់នឹងអារម្មណ៍ នោះ ហើយយើងអាចមានទោសៈ ឬសេចក្តីក្រោធ ជាដើម ចំពោះអារម្មណ៍ ប្រសិនបើយើងបានសម្រេចចិត្តថា វាអាក្រក់ ឬគួរឲ្យស្អប់ខ្ពើម ។ ដូច្នេះ កិលេសទាំងនេះអាចកើតមាននៅក្នុងចិត្តរបស់យើង នៅពេលយើងជួបប្រទះនឹងអ្វីមួយ ។

## នៅពេលយើងមានសតិជាគ្រឿងកំណត់

ដើម្បីការពារកុំឲ្យកិលេសទាំងឡាយកើតឡើងបាន យើងត្រូវការអ្នកការពារ ហើយអ្នកការពារនោះគឺសតិ ។ នៅពេលយើងមានសតិ កិលេសទាំងឡាយនឹងមិនមានឱកាសដើម្បីកើតឡើងនៅក្នុងចិត្តរបស់យើង ។ នៅពេលយើងមានសតិជាគ្រឿងកំណត់ជាអ្នកដឹងខ្លួន និងនៅពេលយើងពិចារណាឃើញអារម្មណ៍ទាំងនោះច្បាស់ យើងដឹងថាអារម្មណ៍ទាំងនោះកើតឡើងហើយវិនាសទៅវិញ អារម្មណ៍ទាំងនោះមិនទៀង ដូច្នេះយើងមិនមានចិត្តជាប់ជំពាក់ទៅនឹងអារម្មណ៍ទាំងនោះ ។ ហេតុដូច្នេះ យើងអាចលះបង់នូវអភិជ្ឈា ឬឧបាទាន ព្រមទាំងទោមនស្ស ឬទោសៈ ចំពោះអារម្មណ៍នោះ ដោយការចម្រើនសតិ ។

ទោះបីយើងនិយាយថា "កម្ចាត់បង់" ឬ "លះបង់" ឬអ្វីក៏ដោយ គឺយើងការពារកុំឲ្យកិលេសទាំងនោះកើតឡើងបាន ។ មិន

មែនថាកិលេសទាំងនោះបានកើតឡើងហើយ ទើបយើងកម្ចាត់បង់ ឬយើងលះបង់បន្ទាប់ពីវាបានកើតឡើងនោះទេ ។ អត្ថន័យគឺការពារពិតប្រាកដកុំឲ្យអភិជ្ឈានិងទោមនស្សកើតឡើងបាន នៅក្នុងចិត្តរបស់យើង ។ ប្រសិនបើយើងមិនចម្រើនសតិទេ មានសតិផ្តោតទៅលើអារម្មណ៍នោះទេ កិលេសទាំងឡាយពិតជាកើតឡើងពោលគឺ អភិជ្ឈា ឬទោមនស្ស ឬឧបាទាន ឬទោសៈ ។ កិលេសទាំងនេះអាចកើតឡើង ប៉ុន្តែដោយការចម្រើនសតិ យើងអាចការពារកុំឲ្យវាកើតឡើងបាន ។ ការពារកិលេសកុំឲ្យកើតមាននៅក្នុងចិត្តរបស់យើងគឺអ្វីដែលហៅថា កម្ចាត់បង់នូវកិលេសបាន ។ (ប៉ុន្តែប្រសិនបើកិលេសទាំងឡាយបានកើតឡើងហើយ ពិតណាស់ យើងគប្បីធ្វើកិលេសទាំងនោះឲ្យទៅជាអារម្មណ៍របស់សតិរបស់យើង ដើម្បីលុបបំបាត់កិលេសទាំងនោះ )។

## កម្ចាត់បង់កិលេសទាំងឡាយ

នៅពេលយើងនិយាយអំពីការត្រាស់ដឹង យើងនិយាយថា "នៅខណៈពេលនៃការត្រាស់ដឹង" កិលេសទាំងឡាយត្រូវបានកម្ចាត់បង់ ។ តើកិលេសអ្វីខ្លះត្រូវបានកម្ចាត់បង់ នៅខណៈនោះ ។ កិលេសក្នុងបច្ចុប្បន្ន កិលេសក្នុងអតីតៈ ឬកិលេសក្នុងអនាគត ។ អតីតៈត្រូវបានកន្លងផុត ដូច្នេះយើងមិនត្រូវធ្វើអ្វីមួយដើម្បីរំលត់

បង់វាទេ ហើយកិលេសក្នុងអនាគតក៏មិនទាន់មកដល់ ដូច្នេះយើង មិនអាចធ្វើអ្វីមួយចំពោះវាបានទេ ។ ចុះចំណែកឯកិលេសក្នុង បច្ចុប្បន្ន ។ ប្រសិនបើកិលេសទាំងឡាយកើតមាន មិនអាចមាន ការត្រាស់ដឹង ពីព្រោះការត្រាស់ដឹងគឺជាកុសលធម៌ ចំណែកឯ កិលេសទាំងឡាយជាអកុលសធម៌ ។ កុសលធម៌និងអកុសលធម៌ មិនអាចកើតឡើងជាមួយគ្នាបានទេ ។ ធម៌ទាំងពីរនេះមិនកើតរួម គ្នាទេ ។ ដូច្នេះ កិលេសទាំងឡាយដែលគេនិយាយថាត្រូវបាន កម្ចាត់បង់ នៅខណៈពេលនៃការត្រាស់ដឹង មិនមែននៅក្នុងអតីតៈ មិននៅក្នុងអនាគត និងមិននៅក្នុងបច្ចុប្បន្ន ។ អីចឹង តើកិលេសអ្វី ត្រូវបានកម្ចាត់បង់ ។ តាមពិត បើនិយាយឲ្យជិតដល់ អ្វីដែលត្រូវ បានកម្ចាត់បង់ គេមិនហៅថាគ្រឿងសៅហ្មង ឬកិលេស ជាភាសា បាលីនោះទេ ។ ទាំងនេះគេហៅថាអនុស័យ (ធម្មជាតិដេកត្រាំនៅ ក្នុងសន្តាន) មានន័យថា ធម្មជាតិមានកម្លាំងដើម្បីកើត ។ អ្វីដែល មគ្គចិត្តកម្ចាត់បង់គឺធម្មជាតិមានកម្លាំងនោះ ។ នៅពេលអ្វីមួយ តែងនៅជាមួយយើង យើងនិយាយថាយើងមានរបស់នោះ ។ ឧទាហរណ៍ ការពិសាបារី ។ ឧបមាថា លោកអ្នកពិសាបារី ប៉ុន្តែ ឥឡូវនេះលោកអ្នកមិនកំពុងពិសាបារីទេ ។ ប្រសិនបើខ្ញុំសួរលោក អ្នកថា "តើអ្នកពិសាបារីឬទេ?"។ លោកអ្នកនិយាយថា "បាទ ខ្ញុំ ពិសាបារី" ពីព្រោះលោកអ្នកពិសាបារីនៅក្នុងអតីតៈ ហើយលោក

អ្នកនឹងពិសានៅក្នុងអនាគត ហើយលោក អ្នកមិនទាន់បានបោះបង់ការពិសាបារីនៅឡើយទេ ។ ដូច្នេះ ទោះបីលោកអ្នកមិនកំពុងពិសាបារីនៅខណៈនោះក៏ដោយ ក៏លោកអ្នកនិយាយថា "ខ្ញុំពិសាបារី "។ ដូចគ្នានេះដែរ ឥឡូវនេះ នៅខណៈនេះ សង្ឃឹមថាខ្លួនខ្ញុំគ្មានកិលេសនៅក្នុងចិត្ត ហើយលោកអ្នកក៏គ្មានកិលេសនៅក្នុងចិត្តរបស់លោកអ្នក ។ ប៉ុន្តែបន្ទាប់ពីធម្មសាកច្ឆា លោកអ្នកចេញទៅក្រៅ ហើយលោកអ្នកជាន់អ្វីមួយ ហើយមុតជើង ឬនរណាម្នាក់ដើរប៉ះលោកអ្នក ហើយលោកអ្នកខឹង ដូច្នេះកិលេសទាំងឡាយកើតមាននៅពេលមានបច្ច័យតាក់តែង ។ ដូច្នេះ យើងនិយាយថា យើងមានកិលេស ។ ខ្ញុំមានកិលេស លោកអ្នកមានកិលេស ប៉ុន្តែមិនមែននៅខណៈនេះទេ ។ ដូច្នេះ "ធម្មជាតិដេកត្រាំនៅក្នុងសន្តាន" គឺអ្វីដែលត្រូវបានលះដោយមគ្គញាណ ការត្រាស់ដឹង ។ កិលេសទាំងឡាយដែលលះខណៈពេលនៃការត្រាស់ដឹងតាមពិតមិនមានអ្វីទេ ប៉ុន្តែគឺធម្មជាតិដេកត្រាំនៅក្នុងសន្តាន ឬធម្មជាតិមានកម្លាំងដើម្បីកើត ។ នៅពេលវាកើតឡើង វានៅទីនោះស្រាប់ ។ ដូចគ្នានេះដែរ "កម្ចាត់បង់នូវអភិជ្ឈានិងទោមនស្ស" ក្នុងទីនេះមានន័យថា ការចៀសវាង ឬការការពារកុំឲ្យកើតមាននៅក្នុងចិត្តរបស់យើង ។ តើត្រូវកម្ចាត់បង់ដោយរបៀបណា ។ ឆ្លើយថា ដោយការចម្រើនសតិប្បដ្ឋាន យើងមានសេចក្ដីព្យាយាម

យើងប្រើសតិ យើងមានសមាធិ ហើយយើងពិចារណាឃើញសភាវៈទាំងឡាយតាមសភាពពិត ។ នៅពេលយើងពិចារណាឃើញសភាវៈទាំងឡាយតាមសភាពពិត កិលេសទាំងឡាយគ្មានឱកាសកើតមាននៅក្នុងចិត្តរបស់យើង ។ តាមវិធីសាស្ត្រនេះ វិបស្សនា ឬសតិប្បដ្ឋានកម្ចាត់បង់នូវកិលេស ។

## ខណិកបហានៈ

ការលះនេះ គឺគ្រាន់តែជាខណៈៗ ដោយធម៌ដែលជាបដិបក្ខ ។ នៅខណៈបន្ទាប់ កិលេសទាំងនោះអាចត្រឡប់មកកើតវិញ ។ វាមានរយៈពេលខ្លី ។ គេហៅថា "ការលះកិលេសដោយធម៌ដែលជាបដិបក្ខ" និង "**ខណិកាបហានៈ**" ជាភាសាបាលី ។ នេះមានន័យថា អ្នកលះអកុសលចេតសិកទាំងឡាយដោយធម៌ដែលជាបដិបក្ខគឺកុសលចេតសិក។ នៅពេលមានកុសលចេតសិកនោះមិនអាចមានអកុសលចេតសិកណាមួយឡើយ ។ លោកអ្នកដម្កល់កុសលចេតសិក ហើយដូច្នេះអកុសលចេតសិកមិនមានឱកាសកើតឡើងទេ ។ នេះលោកហៅថា ការលះកិលេសដោយធម៌ដែលជាបដិបក្ខដែលកើតមានតែមួយខណៈ នៅខណៈបន្ទាប់អកុសលចេតសិកអាចត្រឡប់កើតមានឡើងវិញ ។ ខណៈនៃវិបស្សនា អភិជ្ឈានិងទោមនស្សត្រូវបានលះ តាមរបៀបនេះ ។

នៅពេលអ្នកចេញពីវិបស្សនា ហើយអ្នកជួបប្រទះ នឹងបច្ច័យអាច ឲ្យកិលេសទាំងនោះកើតមាន វានឹងកើតមានឡើង។

## **វិក្ខម្ភនបហានៈ**

មានប្រភេទមួយផ្សេងទៀតនៃការលះកិលេស ហៅថា "**វិក្ខម្ភនបហានៈ**"ការលះកិលេសដោយសង្កត់សង្កិន។ នៅពេលលោកអ្នកសង្កត់អ្វីមួយ វាអាចនៅទីនោះមួយរយៈ វាមិនអាចត្រឡប់មកវិញដោយឆាប់រហ័សនោះទេ ដូចស្មៅនៅក្រោមដុំថ្ម ។ ប្រសិនបើលោកអ្នកសង្កត់ដុំថ្មនៅលើស្មៅ ស្មៅនៅក្រោមដុំថ្ម ប៉ុន្តែបើលោកអ្នកដកដុំថ្មចេញ បន្តិចម្តងៗ វាអាចដុះឡើងវិញ ។ ប្រភេទនៃការលះកិលេសនេះ ហៅថា វិក្ខម្ភនបហានៈ ឬការលះកិលេសដោយសង្កត់សង្កិន ។ ការលះកិលេសនេះជារបស់លោកអ្នកបំពេញឈាន ។ នៅពេលយោគីចូលឈាន យោគីនោះអាចសង្កត់សង្កិនកិលេសមួយរយៈបាន ។ កិលេសមិនអាចកើតមាននៅក្នុងចិត្តរបស់យោគីមួយថ្ងៃ ឬអាចមួយសប្តាហ៍ ឬមួយខែ ប៉ុន្តែនៅក្នុងករណីនេះ វាក៏អាចកើតមានឡើងផងដែរ ។

## **សមុច្ឆេទបហានៈ**

ការលះកិលេសប្រភេទទីបី ហៅថា ការលះកិលេសដោយកាត់ផ្តាច់ ។ ភាសាបាលី **សមុច្ឆេទ** មានន័យថា "ការកាត់ផ្តាច់" រីឯ

**បហានៈ** មានន័យថា ការលះ ដូច្នេះ **សមុច្ឆេទបហានៈ** គឺ ការលះកិលេសដោយការកាត់ផ្តាច់ ។ វាដូចជាលោកអ្នកកាត់ផ្តាច់ ឫសនៃដើមឈើ ដើមឈើមិនអាចលូចលាស់បានទៀតទេ ។ ដូច្នេះ ការលះកិលេសទាំងស្រុង ឬការលះកិលេសតែម្តងនិងទាំង អស់ ហៅថា ការលះកិលេសដោយកាត់ផ្តាច់ ពោលគឺការលះ កិលេសដោយ **លោកុត្តរមគ្គ** ក្នុងខណៈនៃមគ្គនោះ ។ កិលេស ដែលលះក្នុងខណៈនៃមគ្គ មិនអាចកើតមានតទៅទៀតបានទេ ។

ព្រះអរហន្តបានលះកិលេសទាំងអស់ ។ ព្រះអរហន្តគ្មាន ឧបាទាន ការប្រកាន់មាំ គ្មានកោធៈ សេចក្តីក្រោធ គ្មានមានៈ សេចក្តីប្រកាន់ខ្លួន គ្មានឥស្សា សេចក្តីច្រណែនឈ្នានីស ព្រមទាំង គ្មានអកុសលចេតសិកដទៃទៀត ។ ទោះបីគេធ្វើឲ្យខឹង ព្រះអរហន្ត លោកមិនខឹង (មានប្រតិកម្មតប)។ ទោះបីលោកឃើញអារម្មណ៍ គួរឲ្យទាក់ទាញឬស្រស់ស្អាត ព្រះអរហន្តលោកមិនមានអារម្មណ៍ ជាប់ជំពាក់ ឬតណ្ហា សេចក្តីប្រាថ្នាចំពោះអារម្មណ៍នោះទេ ។ ទាំង នោះគឺជាអរិយបុគ្គល ដែលបានលះកិលេសដោយការកាត់ផ្តាច់ ទាំងស្រុង ។

ការលះកិលេសមានបីប្រភេទ ហើយក្នុងទីនេះយើងអាច យល់ដឹងការលះកិលេសពីរប្រភេទ ។ ខ្ញុំបានពន្យល់ការលះ កិលេសទីមួយរួចហើយ ។ ក្នុងទីនេះ អាចមានការលះកិលេសទី

ពីរផងដែរ ។ ប្រសិនបើ លោកអ្នកបានចម្រើនសមាធិបានល្អ ហើយលោកអ្នកអាចកម្ចាត់បង់ នូវអភិជ្ឈានិងទោមនស្សទាក់ទង នឹងអារម្មណ៍ដែលលោកអ្នកកត់សម្គាល់នោះ លោកអ្នកនឹងឃើញ ថា លោកអ្នកអាចកម្ចាត់បង់អភិជ្ឈានិងទោមនស្ស សូម្បីទាក់ទង នឹងអារម្មណ៍ទាំងនោះដែលលោកអ្នកមិនបានកត់សម្គាល់ ។ ក្នុង ទីនេះ "មិនបានកត់សម្គាល់" មានន័យថា មិនបានរៀបចំជាមួយ សតិ ។

តាមធម្មតា អារម្មណ៍ទាំងឡាយដែលយើងជួបប្រទះអាច បង្កឲ្យមានអភិជ្ឈានិងទោមនស្សនៅក្នុងចិត្តរបស់យើង ។ ប្រសិន បើយើងមិនបានចម្រើនសតិប្បដ្ឋានពិចារណាអារម្មណ៍ អ៊ីចឹង យើងមានការប្រកាន់មាំ ឬក៏សេចក្តីព្យាបាទចំពោះអារម្មណ៍នេះ។ ធម្មជាតិនោះកើតឡើងចំពោះមនុស្សភាគច្រើន ។ ប្រសិនបើអ្នក ពូកែចម្រើនវិបស្សនា ហើយអ្នកមានបទពិសោធន៍ក្នុងការលះ អភិជ្ឈានិងទោមនស្សទាក់ទងនឹងអារម្មណ៍ ដែលអ្នកពិចារណា អ្នកឃើញថា អ្នកអាចរារាំងនូវអភិជ្ឈានិងទោមនស្សកុំឲ្យកើត ឡើង សូម្បីទាក់ទងនឹងអារម្មណ៍ទាំងឡាយ ដែលមិនបាន ពិចារណា ។ នេះគឺជាការលះកិលេសដោយសង្កត់សង្កិន ដោយ វិបស្សនា ។

វិបស្សនាអាចសម្រេច បានត្រឹម ការលះកិលេសទាំងពីរ ប្រភេទនេះ ពោលគឺ ខណិកបហានៈ និង វិក្ខម្ភនបហានៈ ។ ប៉ុន្តែ វិបស្សនាមិនអាចសម្រេចបានការលះកិលេសប្រភេទទីបី សមុច្ឆេទបហានៈបានទេ ។ ការលះកិលេសប្រភេទទីបីបានដោយលោកុត្តរមគ្គ ឬមគ្គចិត្ត ក្នុងខណៈនៃមគ្គនោះ ។

ព្រះពុទ្ធសម្តែងថា "កម្ចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោកចេញ" មានន័យថា ភិក្ខុអាចរារាំងកុំឲ្យអភិជ្ឈានិងទោមនស្សកើតឡើងបានទាក់ទងនឹងអារម្មណ៍ដែលភិក្ខុកំពុងពិចារណា ។

## អភិជ្ឈានិងទោមនស្ស

ក្នុងទីនេះ "**អភិជ្ឈា**" សំដៅយកប្រភេទទាំងអស់នៃឧបាទាន លោភៈ រាគៈ និងអកុសលចេតសិកដទៃទៀត រីឯ "**ទោមនស្ស**" សំដៅយកមិនត្រឹមសេចក្តីទុក្ខផ្លូវចិត្តប៉ុណ្ណោះទេ ប៉ុន្តែថែមទាំង សេចក្តីក្រោធ សេចក្តីប្រទូស្ត សេចក្តីសៅហ្មងចិត្ត សេចក្តីសោកផងដែរ ។ ទាំងអស់នេះ រួមនៅក្នុងទោមនស្ស ។ អកុសលមូល មាន ៣ យ៉ាង គឺ **លោភៈ ទោសៈ** និង **មោហៈ** ។ ក្នុងអកុសលមូលទាំង៣ អកុសលមូល២ មានសម្តែងនៅទីនេះ ។ អភិជ្ឈា គឺអកុសលមូល ទី ១ ដែលជាលោភៈ ឬសេចក្តីចង់បាន

និងអកុសលមូលទី ២ គឺ ទោសៈ ។ ដូច្នេះ ចំពោះអភិជ្ឈាយើង សំដៅយកក្រុមលោភៈចេតសិកទាំងអស់ រីឯចំពោះទោមនស្ស យើងសំដៅយកក្រុមទោសៈចេតសិកទាំងអស់ ។ មោហៈ ឬអវិជ្ជា មិនមានរួមបញ្ចូលនៅទីនេះ ពីព្រោះមោហៈពិបាកការពារ និង ពិបាកលះណាស់ ។ ដូច្នេះ នៅក្នុងឃ្លានេះ យើងគប្បីយល់ថា ភិក្ខុក្នុងសាសនានេះ ពិចារណាឃើញនូវកាយក្នុងកាយជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ មានព្យាយាម ជាគ្រឿងដុតកម្ដៅកិលេស ជាអ្នកដឹងខ្លួន មានសមាធិចិត្ត មានស្មារតី ជាគ្រឿងកំណត់ ក្នុង ពេលដំណាលគ្នា ភិក្ខុអាចកម្ចាត់បង់នូវអភិជ្ឈានិងទោមនស្ស ។ ការពិចារណាពី វេទនា ពីចិត្ត ពីធម៌ ក៏ដូចគ្នា ។ (អដ្ឋកថាសម្ដែង ថា "កម្ចាត់បង់នូវអភិជ្ឈានិងទោមនស្ស សំដៅយកការកម្ចាត់បង់ នូវនីវរណធម៌ទាំងប្រាំ ពីព្រោះនៅពេលអភិជ្ឈានិងទោមនស្ស ដែលជាធម៌មាន កម្លាំងខ្លាំងបំផុតក្នុងចំណោមនីវរណធម៌ប្រាំត្រូវ បានសម្ដែង យើងគប្បីយល់ថា នីវរណធម៌ដទៃទៀតក៏បាន សម្ដែងផងដែរ )។

## សតិប្បដ្ឋាន ៤

លោកអ្នកដឹងសតិប្បដ្ឋាន ៤ ការតម្កល់សតិ ៤ យ៉ាង ។ សតិប្បដ្ឋានមាន ៤ ពីព្រោះមានអារម្មណ៍ ៤ ។ អារម្មណ៍ទី ១ គឺ

កាយ ។ ជួនកាល "**កាយ**" មិនមែនតែមានន័យថា រាងកាយទាំងមូលនោះទេ គឺសំដៅយកក្រុមនៃរូបធម៌មួយចំនួនប៉ុណ្ណោះ ការដកដង្ហើមក៏ហៅថាកាយផងដែរ ។ ភាគផ្សេងៗនៃរាងកាយក៏ហៅថាកាយដែរ ។ ពាក្យថា "កាយ" យើងគប្បីយល់ថា អ្វីៗដែលកើតរួមជាមួយកាយ ។

អារម្មណ៍ទី ២គឺ **វេទនា**។ វេទនាជាចេតសិក។ ឧទាហរណ៍ យើងឈឺចុកចាប់នៅទីនេះ ការឈឺចុកចាប់ផ្នែករាងកាយ យើងដឹងសេចក្តីឈឺចុកចាប់រាងកាយ ដោយចិត្តរបស់យើង ។ នៅក្នុងចិត្តរបស់យើងមានចេតសិកមួយ ហៅថា វេទនា ។ ដោយវាជាទុក្ខវេទនាគឺទុក្ខវេទនា ។ នៅពេលព្រះពុទ្ធទ្រង់សម្តែងថា "ភិក្ខុក្នុងសាសនានេះ ពិចារណាឃើញនូវវេទនាក្នុងវេទនាទាំងឡាយជាប្រក្រតី" មានន័យថា ភិក្ខុពិចារណានូវចេតសិកនោះ មិនចាំបាច់ពិចារណានូវការឈឺចុកចាប់នៅត្រង់កន្លែងនោះទេ ។ នៅក្នុងការប្រតិបត្តិ នៅពេលយើងឈឺចុកចាប់ យើងគប្បីនិយាយថា "ផ្តោតអារម្មណ៍លើការឈឺចុកចាប់ និងមានស្មារតីកំណត់សម្គាល់ការឈឺចុកចាប់ ពីព្រោះនោះជាការប្រតិបត្តិ ។ ប៉ុន្តែតាមពិត នៅពេលដែលយើងកត់សម្គាល់ថា "ឈឺចុកចាប់ ឈឺចុកចាប់" យើងពិតជាកត់សម្គាល់លើចេតសិក ដែលមានអារម្មណ៍ឈឺចុកចាប់នៅក្នុង

រាងកាយ ។ វេទនានេះមាន ៣ ប្រភេទ គឺ សុខ ទុក្ខ និង អព្យាក្រឹត (មិនសុខមិនទុក្ខ )។

អារម្មណ៍ទី ៣ គឺ **ចិត្ត** ។ ចិត្តជាពាក្យបាលី ។ ចិត្តជានាមធម៌ ។ នៅក្នុងចិត្តវិទ្យាពុទ្ធសាសនា **នាមធម៌** មាន ៤ គឺ **វេទនា សញ្ញា សង្ខារ** និង **វិញ្ញាណ** ។ អ្វីដែលយើងហៅថានាមធម៌ គឺជាក្រុម ឬការផ្សំសភាវៈ ៤ ។ជួនកាល អាចមានការយល់ច្រឡំពាក្យ "**នាមធម៌**" និង ពាក្យ "**ចិត្ត**" ។ យើងនិយាយថា នាមធម៌មានចិត្ត និងចេតសិក ។ ចិត្តជាធម្មជាតិដឹងនូវអារម្មណ៍ ។ ការដឹងក្នុងទីនេះ មិនដូចការដឹងនៅក្នុងការចម្រើនសមាធិទេ ។ វាគ្រាន់តែការដឹងប៉ុណ្ណោះ ។ វាដូចនៅពេលខ្ញុំដឹងនរណាម្នាក់នៅទីនោះទោះបី ខ្ញុំកំពុងសំឡឹងមើលរបៀបនេះក៏ដោយ ។ ការដឹងប្រភេទនេះ ហៅថា ចិត្ត ។ យ៉ាងហោចណាស់ នៅក្នុងអភិធម្ម លោកហៅថា ចិត្ត ។ ពាក្យថា ចិត្ត អាចមានន័យច្រើនជាងនេះ ខ្ញុំដឹងមិនច្បាស់ដែរ ។

ចិត្តគឺជាធម្មជាតិដែលដឹងនូវអារម្មណ៍ ។ ត្រឹមតែនៅពេលមានការដឹងនូវអារម្មណ៍ អាចមានការប៉ះទង្គិចជាមួយអារម្មណ៍ ការដឹងនូវអារម្មណ៍តាមផ្លូវចិត្ត ការចូលចិត្តនឹងអារម្មណ៍ ការមិនចូលចិត្តនឹងអារម្មណ៍ ជាដើម ។ ដូច្នេះធម្មជាតិទាំងនេះ (ចេតសិក) បន្ទាប់បន្សំពីចិត្ត ប៉ុន្តែវាក៏ជាធាតុផ្សំនៃចិត្តដែរ ។

ម្យ៉ាងទៀត នាមធម៌ចែកចេញជាពីរ គឺចិត្តនិងចេតសិក ។ **ផស្សោ** សភាពជាអ្នកធ្វើនូវអារម្មណ៍ឲ្យពាល់ត្រូវនូវទ្វារ **វេទនា** ធម្មជាតិសោយនូវអារម្មណ៍ **សញ្ញា** ធម្មជាតិចាំ ឬកត់នូវអារម្មណ៍ **ចេតនា** ធម្មជាតិគិតដឹកនាំចិត្ត ឬសន្សំនូវបុណ្យនិងបាប **ការចូល ចិត្ត** និង **ការមិនចូលចិត្ត** ជាដើម ទាំងអស់នេះ ហៅថា ចេតសិក ។ នៅក្នុងអភិធម្ម ចេតសិកមាន ៥២ ចែកចេញជាបីក្រុម គឺ **វេទនា សញ្ញា** និង **សង្ខារ** ។ នៅពេលយើងបន្ថែមវិញ្ញាណ (**ចិត្ត**) យើងបាននាមធម៌ ៤ ប្រភេទ ។ គួរជាទីជឿងឆ្ងល់ដែលថា ព្រះពុទ្ធអាចពន្យល់និងញែកឲ្យឃើញភាពខុសគ្នានៃនាមធម៌នីមួយៗ ដែលកើតឡើងក្នុងពេលជាមួយគ្នា សំដៅយកវត្ថុដូចគ្នាជាអារម្មណ៍ ។

នៅពេលយើងចម្រើនសមាធិ យើងពិចារណាថា "សោកស្តាយ សោកស្តាយ" នោះមានន័យថា យើងមានចិត្តប្រកបដោយសេចក្តីសោក ។ វាអាចជាការពិចារណានូវចិត្ត ។ នៅពេលខ្ញុំនិយាយថា "ខឹង ខឹង" ខ្ញុំកំពុងពិចារណានូវចិត្ត ។

អារម្មណ៍ចុងក្រោយ គឺ **ធម៌** ។ ធម៌ជាពាក្យបាលីមួយដែលពិបាកបកប្រែបំផុត ឬមិនអាចបកប្រែឲ្យពេញអត្ថន័យ (ជាភាសាដទៃ)។ ធម៌មានន័យផ្សេងៗគ្នា ក្នុងបរិបទផ្សេងគ្នា ។ លោកអ្នកមិនអាចបកប្រែពាក្យនេះ ដោយពាក្យខ្មែរមួយម៉ាត់បានទេ ។ ប្រសិនបើលោកអ្នកហ៊ាន លោកអ្នកនឹងខុស ។ ក្នុងទីនេះ

ធម្ម ឬ ធម៌ ធម្មតាមានន័យថា ធម្មជាតិទាំងឡាយ ដែលជា **នីវរណធម៌ ៥ បញ្ចក្ខន្ធ ខន្ធ ៥ អាយតនៈ ១២ ពោជ្ឈង្គៈ ៧** និង **អរិយសច្ច៤**។ ទាំងនេះហៅថាធម៌ នៅក្នុងព្រះសូត្រនេះ។ ដូច្នេះ យើងមិនអាច បកប្រែពាក្យនេះបានទេ ។ ភាគច្រើនធម៌ បកប្រែថា "ធម្មជាតិ" ឬ "សភាវៈ" ប៉ុន្តែការបកប្រែនីមួយៗមិនទាន់ជាទីពេញចិត្តនៅឡើយ ។ ហេតុនេះ រក្សាពាក្យនេះមិនបកប្រែជាការប្រសើរ ដើម្បីកុំឲ្យច្រឡំ ។ ប្រសិនបើយើងបកប្រែថា "អារម្មណ៍របស់ចិត្ត" យើងសំដៅថា "ចិត្តជាអារម្មណ៍" ដូច្នេះ អារម្មណ៍ខ្វះមិនមែនជាចិត្ត ។ ប្រសិនបើ យើងបកប្រែថា "អារម្មណ៍របស់ចិត្ត" ដូច្នេះអ្វីៗទាំងអស់ជាអារម្មណ៍របស់ចិត្ត ។ កាយក៏ជាអារម្មណ៍របស់ចិត្ត ផងដែរ ។ ដោយសារ យើងមិនអាចទទួលបានការបកប្រែជាទីពេញចិត្ត និងគ្រប់គ្រាន់អត្ថន័យ គប្បីទុកកុំបកប្រែ ។

## ពិចារណានូវធម៌

ពិចារណានូវធម៌ ពោលគឺ ប្រសិនបើលោកអ្នកផ្តោតអារម្មណ៍លើកំហឹង ដូច្នេះ លោកអ្នកកំពុងពិចារណានូវធម៌ ។ ក្នុងទីនេះ ធម៌ មិនមានន័យថា ពាក្យប្រៀនប្រដៅ ឬព្រះសូត្រ ឬអ្វីៗផ្សេងៗទៀតទេ ។ ប្រសិនបើលោកអ្នកឃើញអ្វីមួយ ហើយលោក

អ្នកមានសតិលើការឃើញ ដូច្នេះ លោកអ្នកកំពុងចម្រើន **ធម្មានុបស្សនា** ការពិចារណាឃើញនូវធម៌ ។ម្យ៉ាងទៀត ធម្មានុបស្សនា ទូលំទូលាយណាស់ រួមមាន នីវរណធម៌ ខន្ធ អាយតនៈ ពោជ្ឈង្គៈ និង អរិយសច្ច ៤ ។

## នៅក្នុងការប្រតិបត្តិ

ខ្ញុំបានសម្ដែងរួចហើយថា លោកអ្នកចម្រើនសតិប្បដ្ឋាន ៤ គឺ កាយ វេទនា ចិត្ត និង ធម៌ ព្រាវៗ ដូច្នេះ នៅពេលលោកអ្នកកំពុងប្រតិបត្តិពិតប្រាកដ ចូរកុំព្យាយាមរកឲ្យឃើញថា សតិប្បដ្ឋានមួយណាដែលលោកអ្នកកំពុងចម្រើន ។ នេះជាការធ្វើឲ្យស្មារតីមិនមូល ។ អ្នកចម្រើនវិបស្សនាគប្បីយកអ្វីដែលមាននៅខណៈពេលបច្ចុប្បន្ន ។ ចូរកុំព្យាយាមរកឲ្យឃើញថា តើជាកាយ ឬវេទនា ឬចិត្ត ឬក៏ធម៌ ។ អ្វីក៏ដោយដែលកើតឡើង ភារកិច្ចរបស់លោកអ្នកសំខាន់គឺមានសតិចំពោះអារម្មណ៍ ដែលកំពុងកើតឡើងនោះ ធ្វើដូច្នេះលោក អ្នកមិនមានអភិជ្ឈានិងទោមនស្សចំពោះអារម្មណ៍នោះឡើយ ។

ដើម្បីកុំឲ្យមានអភិជ្ឈានិងទោមនស្ស អ្នកគប្បីមានសតិ ។ លោកអ្នកគ្មានពេលដើម្បីរកឲ្យឃើញថា តើវាជាចិត្តរបស់ធម៌ ឬអ្វីផ្សេង ។ នៅពេលលោកអ្នកចម្រើនវិបស្សនា លោកអ្នកចម្រើន

សតិប្បដ្ឋានទាំងអស់៤នេះ ពេលដែលវាមកជាមួយ ។ ពេលណាដែលអ្នកមានសតិចំពោះអារម្មណ៍នៅខណៈពេលបច្ចុប្បន្ន អ្នកប្រតិបត្តិបានល្អ សមាធិរបស់អ្នកល្អ ។ អ្វីដែលមិនល្អគឺនៅពេលការគិតរបស់អ្នកនាំអ្នកទៅឆ្ងាយ ហើយអ្នកភ្លេចសមាធិចិត្តរបស់អ្នកប្អូនដប់វិនាទី ឬអាចមួយនាទី ។ នោះមិនល្អទេ ។ ប៉ុន្តែនៅពេលដែលអ្នកមានសតិ អ្នកធ្វើបានត្រឹមត្រូវ សមាធិចិត្តរបស់អ្នកប្រព្រឹត្តទៅបានល្អ ។ ជួនកាល យោគីនិយាយថា "អូ! យើងត្រូវចំណាយពេល ឬខាតពេលវេលាកត់សម្គាល់ចិត្ត ដែលទៅនេះទៅនោះ ហើយយើងគ្មានពេលវេលាច្រើន ដើម្បីផ្ដោតទៅលើអារម្មណ៍ចំបង (អារម្មណ៍ចំបងគឺសំដៅយកអារម្មណ៍មូលដ្ឋានត្រឹះខាងដើម ក្នុងការចម្រើនវិបស្សនា)"។ ទោះបីអ្នកដឹងច្បាស់នូវអារម្មណ៍ចំបង ឬបន្ទាប់បន្សំក៏ដោយ ពេលដែលអ្នកមានសតិគ្រប់ខណៈ អ្នកធ្វើបានល្អ ។ អ្នកកំពុងធ្វើសមាធិ ឬចម្រើនវិបស្សនា ។ អ្វីដែលសំខាន់នៅក្នុងការចម្រើនវិបស្សនា ដំបូងគឺមានសតិដឹងអារម្មណ៍នៅខណៈពេលបច្ចុប្បន្ន ។ ជួនកាល អ្នកអាចភ្លេចបាត់សតិ អីចឹងការភ្លេចនោះក៏ ក្លាយជាអារម្មណ៍នៃការចម្រើនផងដែរ ។ អ្នកគប្បីនិយាយដាក់ខ្លួនឯងថា "ភ្លេច ភ្លេច" ឬអ្វីៗដែលដូចនេះ មុននឹងអ្នកត្រឡប់ទៅ អារម្មណ៍ដើម (អារម្មណ៍ចំបង )។

គប្បីមានសតិជានិច្ចជាកាល ពោលគឺ សតិទីនេះ សតិទីនោះ ហើយប្រសិនបើអ្នកអាចរក្សាសតិរបស់អ្នកខ្លាំងក្លា អ៊ីចឹងអ្នកនឹងធ្វើឲ្យចម្រើនយ៉ាងរហ័ស ហើយអ្នកនឹងចាប់ផ្ដើមមើលឃើញធម្មជាតិតាមសភាវៈពិត ។ នោះគឺលោកអ្នកចាប់ផ្ដើមឃើញអារម្មណ៍ទាំងឡាយ ដែលកើតឡើងនិងរលត់ទៅវិញ ។ នៅពេលអ្នកឃើញការកើតឡើងនិងរលត់ទៅវិញ អ្នកក៏មើលឃើញផងដែរថា វាមិនទៀង ។ ពេលអ្នកឃើញថា វាមិនទៀង អ្នកក៏ឃើញធម្មជាតិជាទុក្ខរបស់វាផងដែរ និងធម្មជាតិមិនមែនរបស់ខ្លួន ឬអ្នកគ្មានការគ្រប់គ្រងលើធម្មជាតិទាំងនេះ និងឃើញថា វាកើតឡើងនិងរលត់ទៅវិញតាមទំនើងសេរីរបស់វា ។ ដូច្នេះ ពេលអ្នកឃើញធម្មជាតិទាំងនេះ គេហៅថា អ្នកឃើញនូវសាមញ្ញលក្ខណៈ ៣ យ៉ាងរបស់សង្ខារធម៌ទាំងអស់។ ការមើលឃើញសាមញ្ញលក្ខណៈទាំង ៣ យ៉ាងនេះនៃសង្ខារធម៌ទាំងអស់ គឺជាខ្លឹមនៃវិបស្សនា ។ ប្រសិនបើលោកអ្នកចម្រើនវិបស្សនា អ្នកគប្បីមើលឃើញនូវសាមញ្ញលក្ខណៈទាំង ៣ នេះ ពីព្រោះពាក្យថា វិបស្សនា មានន័យថា ធម្មជាតិឃើញដោយអាការៈផ្សេងៗ ហើយ "ធម្មជាតិឃើញដោយអាការៈផ្សេងៗ" មានន័យថា ការឃើញសភាពមិនទៀង សភាពជាទុក្ខ និងសភាពមិនមែនជារបស់ខ្លួន ។ អ្វីដែលសំខាន់នៅក្នុងវិបស្សនា គឺមើលឃើញលក្ខណៈទាំង ៣ នេះ

ហើយដើម្បីឃើញលក្ខណៈទាំង ៣ នេះ ចាំបាច់យើងត្រូវកត់សម្គាល់ ពោលគឺ យើងត្រូវមើល និងផ្តោតអារម្មណ៍លើអារម្មណ៍ក្នុងខណៈពេលបច្ចុប្បន្ន ។

ដើម្បីផ្តោតអារម្មណ៍លើអារម្មណ៍ ក្នុងខណៈពេលបច្ចុប្បន្ន យើងត្រូវការសេចក្តីព្យាយាម ។ បើគ្មានសេចក្តីព្យាយាម គឺគ្មានអ្វីមានប្រយោជន៍អាចសម្រេចបាននោះទេ ។ ហេតុនេះ ទើបព្រះពុទ្ធទ្រង់សម្តែងថា "មានព្យាយាមជាគ្រឿងដុតកម្តៅកិលេស ជាអ្នកដឹងខ្លួន មានស្មារតីជាគ្រឿងកំណត់ "។ នៅពេលយើងអាចបំពេញបាននូវល័ក្ខខ័ណ្ឌទាំងនេះ ពោលគឺ មានព្យាយាម ជាគ្រឿងដុតកម្តៅកិលេស ជាអ្នកដឹងខ្លួន មានស្មារតីជាគ្រឿង កំណត់ និងមានសមាធិ យើងអាចកម្ចាត់បង់នូវអភិជ្ឈានិង ទោមនស្សទាក់ទងនឹងអារម្មណ៍ដែលយើងសង្កេតពិនិត្យ និង កត់សម្គាល់ ។

## អានិសង្សនៃការចម្រើនសតិប្បដ្ឋាន

ម្នាលភិក្ខុទាំងឡាយ បើបុគ្គលណាមួយ បានចម្រើនសតិប្បដ្ឋានទាំង ៤ នេះ អស់ ៧ ឆ្នាំ តាមលំដាប់នៃវិធីចម្រើនដែលតថាគតបានពោលហើយ យ៉ាងនេះ បណ្តាផលទាំងឡាយពីរ ផលណាមួយ ក៏គង់នឹងបានសម្រេចដល់បុគ្គលនោះ តាមសេចក្តីប្រាថ្នាដោយពិត គឺថា នឹងបានសម្រេចនូវភាវៈជាព្រះ

អរហន្ត ក្នុងបច្ចុប្បន្នទាន់ភ្នែក ពុំនោះសោត បើមានឧបាទានក្ខន្ធសេសសល់នៅ ក៏គង់នឹងបានសម្រេចនូវភាវៈជាអនាគាមិបុគ្គលពុំខានឡើយ ។

ម្នាលភិក្ខុទាំងឡាយ កុំថាដល់ទៅ អស់ ៧ ឆ្នាំឡើយ ។ ម្នាលភិក្ខុទាំងឡាយ សូម្បីបុគ្គលណាមួយ បានចម្រើនសតិប្បដ្ឋានទាំង ៤ នេះ អស់ ៦ ឆ្នាំ តាមលំដាប់នៃវិធីចម្រើន ដែលតថាគតបានពោលហើយយ៉ាងនេះ ។ អស់ ៥ ឆ្នាំ ។ អស់ ៤ ឆ្នាំ ។ អស់ ៣ ឆ្នាំ ។ អស់ ២ ឆ្នាំ ។ អស់ ១ ឆ្នាំ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ កុំថាដល់ទៅអស់ ១ ឆ្នាំឡើយ ។ ម្នាលភិក្ខុទាំងឡាយ សូម្បីបុគ្គលណាមួយ បានចម្រើនសតិប្បដ្ឋាន ទាំង ៤ នេះ អស់ ៧ ខែ តាមលំដាប់នៃវិធីចម្រើន ដែលតថាគតបានពោលហើយយ៉ាងនេះ បណ្ដាផលទាំងឡាយពីរ ផលណាមួយ ក៏គង់នឹងបានសម្រេចដល់បុគ្គលនោះ តាមសេចក្ដីប្រាថ្នាដោយពិត គឺថា នឹងបានសម្រេចនូវភាវៈជាព្រះអរហន្ត ក្នុងបច្ចុប្បន្នទាន់ភ្នែក ពុំនោះសោត បើមានឧបាទានក្ខន្ធ សេសសល់នៅ ក៏គង់នឹងបានសម្រេចនូវភាវៈជាអនាគាមិបុគ្គល ពុំខានឡើយ ។

ម្នាលភិក្ខុទាំងឡាយ កុំថាដល់ទៅ អស់ ៧ ខែឡើយ ។ ម្នាលភិក្ខុទាំងឡាយ សូម្បីបុគ្គលណាមួយ បានចម្រើនសតិប្បដ្ឋានទាំង ៤ នេះ អស់ ៦ ខែ តាមលំដាប់នៃវិធីចម្រើន ដែលតថាគត

បានពោលហើយយ៉ាងនេះ ។ អស់ ៥ ខែ ។ អស់ ៤ ខែ ។ អស់ ៣ ខែ ។ អស់ ២ ខែ ។ អស់ ១ ខែ ។ អស់ កន្លះខែ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ កុំថា ដល់ទៅអស់ កន្លះខែឡើយ ។ ម្នាលភិក្ខុទាំងឡាយ សូម្បីបុគ្គលណាមួយ បានចម្រើនសតិប្បដ្ឋាន ទាំង ៤ នេះ អស់ ៧ ថ្ងៃ តាមលំដាប់ នៃវិធីចម្រើន ដែលតថាគតបានពោលហើយយ៉ាងនេះ បណ្តាផលទាំងឡាយពីរ ផលណាមួយក៏គង់នឹងបានសម្រេចដល់ បុគ្គលនោះ តាមសេចក្តីប្រាថ្នាដោយពិត គឺថានឹងបានសម្រេច នូវភាវៈជាព្រះអរហន្ត ក្នុងបច្ចុប្បន្នទាន់ភ្នែក ពុំនោះសោត បើមាន ឧបាទានក្ខន្ធ សេសសល់នៅ ក៏គង់នឹងបានសម្រេចនូវភាវៈជា អនាគាមិបុគ្គល ពុំខានឡើយ ។

## ពីព្រោះហេតុនេះ ព្រះពុទ្ធទ្រង់សម្តែងថា

ម្នាលភិក្ខុទាំងឡាយ ផ្លូវគឺសតិប្បដ្ឋានទាំង ៤ នេះ ជាផ្លូវមូលតែមួយ ប្រព្រឹត្តទៅ ដើម្បីសេចក្តីបរិសុទ្ធដោយវិសេសនៃសត្វទាំងឡាយ ដើម្បីកន្លងបង់នូវសេចក្តីសោកនិងសេចក្តីខ្សឹកខ្សួលរំជួលចិត្តទាំងឡាយ ដើម្បីរលត់ទៅនៃទុក្ខនិងទោមនស្សទាំងឡាយ ដើម្បីដល់នូវអរិយមគ្គជាធម៌សម្រាប់ស្រោចស្រង់ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន ។

## សតិប្បដ្ឋានទាំង ៤ តើអ្វីខ្លះ ។

ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ពិចារណាឃើញនូវកាយក្នុងកាយជាប្រក្រតី គ្រប់ឥរិយាបទទាំង ៤ មានព្យាយាមជាគ្រឿងដុតកម្ដៅកិលេស ជាអ្នកដឹងខ្លួន មានស្មារតី (ជាគ្រឿងកំណត់) កម្ចាត់បង់ នូវអភិជ្ឈានិងទោមនស្ស ក្នុងលោកចេញ ១

ពិចារណាឃើញនូវវេទនាក្នុងវេទនាទាំងឡាយ ជាប្រក្រតី គ្រប់ឥរិយាបទទាំង ៤ មានព្យាយាមជាគ្រឿងដុតកម្ដៅកិលេស ជាអ្នកដឹងខ្លួន មានស្មារតី (ជាគ្រឿងកំណត់) កម្ចាត់បង់នូវអភិជ្ឈានិងទោមនស្ស ក្នុងលោកចេញ ១

ពិចារណាឃើញនូវចិត្តក្នុងចិត្តជាប្រក្រតី គ្រប់ឥរិយាបទទាំង ៤ មានព្យាយាមជាគ្រឿងដុតកម្ដៅកិលេស ជាអ្នកដឹងខ្លួន មានស្មារតី (ជាគ្រឿងកំណត់) កម្ចាត់បង់ នូវអភិជ្ឈា និងទោមនស្ស ក្នុងលោកចេញ ១

ពិចារណាឃើញនូវធម៌ក្នុងធម៌ទាំងឡាយ ជាប្រក្រតី គ្រប់ឥរិយាបទទាំង ៤ មានព្យាយាមជាគ្រឿងដុតកម្ដៅកិលេស ជាអ្នកដឹងខ្លួន មានស្មារតី (ជាគ្រឿងកំណត់) កម្ចាត់បង់នូវអភិជ្ឈានិងទោមនស្ស ក្នុងលោកចេញ ១ ។